00275469

C40/5/2

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅចំពោះមុខអង្គបុរេជំនុំជម្រះ

| | | |
|---|---|---|
| សំណុំរឿងលេខ | ៖ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៤) |
| កាលបរិច្ឆេទនៃការបញ្ជូន | ៖ | ថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ |
| ភាគីបញ្ជូន | ៖ | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម | ៖ | អង់គ្លេស |
| ប្រភេទឯកសារ | ៖ | សាធារណៈ (ឯកសារដែលបានលុបចោលខ្លះ) |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 28 / 01 / 2009
ម៉ោង (Time/Heure): 13:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## ឯកសារដែលបានលុបខ្លះសម្រាប់សាធារណៈនៃចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅនឹងសារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាបដិសេធការដោះលែងឲ្យមានសេរីភាព ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨" របស់ ខៀវ សំផន បានដាក់ជូនកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩

**បញ្ជូនដោយ៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក ពេជ្រ សម្បត្តិ

លោក Vincent de WILDE d'ESTMAEL

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 27 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C. A. Ny

**ចែកចាយជូន៖**

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន, ប្រធាន

ចៅក្រម Rowan DOWNING

ចៅក្រម ន័យ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ ខៀវ សំផន៖**

លោក សរ សូវាន

លោក Jacques VERGÈS

C40/5/2

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ១៤)*

## ១. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញា ឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ("បណ្តឹងឧទ្ធរណ៍")[1] ដែលបានដាក់កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៨ ដើម្បីស្វែងរកឲ្យមានការកែប្រែលើដីការបស់សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ដែលបដិសេធសំណើសុំការដោះលែងឲ្យមានសេរីភាពជាបន្ទាន់ ("ដីកាបដិសេធការដោះលែង") របស់ ខៀវ សំផន ("ជនត្រូវចោទ" ឬ "ដើមបណ្តឹងឧទ្ធរណ៍")[2] ។ បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីនេះ បានដាក់ស្របតាមវិធាន៦៤.២ និងវិធាន៧៤.៣.ច នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ។ មេធាវីការពារក្តីអះអាងថា ជនត្រូវចោទគួរតែត្រូវបានដោះលែង ដោយសារ (១) សេចក្តីសម្រេចរបស់ ស.ច.ស មានការពារព័ន្ធទៅនឹងកំហុសឆ្គងផ្នែកច្បាប់ ដូចដែលសេចក្តីសម្រេចនេះ មិនបានគិតគូរទៅលើកាលៈទេសៈទាំងមូលនៃករណីដើម្បីយកមកធ្វើជាយុត្តិកម្ម និងដោយសារតែឈរទៅលើតែមូលដ្ឋានទម្ងន់នៃបទឧក្រិដ្ឋនានាដែលបានចោទប្រកាន់តែប៉ុណ្ណោះ[3] ។ (២) សេចក្តីសម្រេចរបស់ ស.ច.ស មានការពាក់ព័ន្ធទៅនឹងកំហុសឆ្គងផ្នែកអង្គហេតុ ដូចដែលសេចក្តីសម្រេចនេះ មិនបានបង្ហាញភស្តុតាងឲ្យឃើញអំពីហានិភ័យពិតប្រាកដនៃការគាបសង្កត់ ទៅលើសាក្សី និងជនរងគ្រោះ ហានិភ័យនៃការធ្វើឲ្យខូចសណ្តាប់ធ្នាប់សាធារណៈ ឬ ហានិភ័យចំពោះសុវត្ថិភាពផ្ទាល់ខ្លួន[4], (៣) ការដោះលែង គឺជាវិធានការសមស្របតែមួយគត់[5] និងគ្មានឧបសគ្គសម្រាប់ការដោះលែងដើមបណ្តឹងឧទ្ធរណ៍ឡើយ[6], និងថា (៤) ការឃុំខ្លួនដើមបណ្តឹង

---

[1] *ករណីរបស់ ខៀវ សំផន,* សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធដោះលែងឲ្យមានសេរីភាព, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨" របស់ ខៀវ សំផន, សារណាបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨, C40/5/1, ERN 00269865-82 (ភាសាអង់គ្លេស) និង ERN 00242969-94 (ភាសាខ្មែរ) [(*ចាប់ពីនេះតទៅហៅថា* បណ្តឹងឧទ្ធរណ៍] ។

[2] *ករណីរបស់ ខៀវ សំផន,* ដីកាសម្រេចបដិសេធសំណើសុំដោះលែងឲ្យមានសេរីភាព, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨, C40/4, ERN 00236261-71 (ភាសាអង់គ្លេស) និង 00235045-65 (ភាសាខ្មែរ) [(*ចាប់ពីនេះតទៅហៅថា* ដីកាបដិសេធការដោះលែង)]; សំណើសុំឲ្យមានការដោះលែងឲ្យមានសេរីភាពជាបន្ទាន់ របស់ មេធាវីការពារក្តី ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨, C40, ERN 00233119-30 (ភាសាអង់គ្លេស), ERN 00228906-18 (ភាសាបារាំង) និង 00228887-905 (ភាសាខ្មែរ) [(ចាប់ពីនេះតទៅហៅថា សំណើសុំដោះលែងជាបន្ទាន់របស់មេធាវីការពារក្តី")] ។

[3] បណ្តឹងឧទ្ធរណ៍, C40/5/1, កថាខ័ណ្ឌទី៣, ២៣-៤២ ។

[4] បណ្តឹងឧទ្ធរណ៍, C40/5/1, កថាខ័ណ្ឌទី៤, ៤៣-៨០ ។

[5] បណ្តឹងឧទ្ធរណ៍, C40/5/1, កថាខ័ណ្ឌទី៥, ៨១-៨៣ ។

[6] បណ្តឹងឧទ្ធរណ៍, C40/5/1, វាក្យខ័ណ្ឌ ខ, កថាខ័ណ្ឌទី៤៣-៨០ ។

ឧទ្ធរណ៍មានរយៈពេលលើសពីមួយឆ្នាំហើយ ហើយដំណើរការនីតិវិធីមានកង្វះខាតលើការយកចិត្តទុកដាក់[7] ។

២. សហព្រះរាជអាជ្ញា ស្នើដល់អង្គបុរេជំនុំជម្រះ ("អ.ប.ជ") បដិសេធចោលបណ្តឹងឧទ្ធរណ៍នេះ ដោយឈរលើទឡ្ហីករណ៍ដូចតទៅ៖

(ក) ដោយសារបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការដោះលែងបណ្តោះអាសន្ន វាគឺជាបន្ទុករបស់ជនត្រូវចោទ ដើម្បីបង្ហាញភស្តុតាងឱ្យឃើញថា កត្តានានាដែលកំពុងយកធ្វើជាយុត្តិកម្មសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន មិនមានទៀតឡើយ ។

(ខ) ដីកាបដិសេធការដោះលែង គឺបានផ្តល់សំអាងហេតុដែលមានលក្ខណៈគ្រប់គ្រាន់ និងសមល្មមថា ស.ច.ស បានដាក់ចេញដោយគិតគូរអំពីទឡ្ហីករណ៍ផ្នែកច្បាប់ និងអង្គហេតុ មុននឹងចេញដីកាសម្រេចបន្តការឃុំខ្លួន និងក៏មិនជាប់កាតព្វកិច្ចត្រូវបញ្ជាក់ពី កត្តានានាទាំងអស់នោះដែរ ។

(គ) រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន មិនមែនគ្មានមូលហេតុនោះទេ ហើយក៏គ្មានកង្វះការយកចិត្តទុកដាក់ហ្មត់ចត់របស់ ស.ច.ស ក្នុងការអនុវត្តន៍កិច្ចដំណើរការនីតិវិធី ។

(ឃ) បញ្ហានៃសិទ្ធិ និងកាតព្វកិច្ចនៃការបកប្រែសរសេរ គឺជារឿងដាច់ដោយឡែកពីបញ្ហានៃនីត្យានុកូលភាពនៃការឃុំខ្លួនបណ្តោះអាសន្ន និងការរង់ចាំនៅចំពោះមុខ អ.ប.ជ នាពេលបច្ចុប្បន្ន ។ អំណះអំណាងដដែលៗនៅលើបញ្ហានេះ នៅក្នុងសារណាបន្តបន្ទាប់គ្នារបស់មេធាវីការពារក្តី គឺមិនពាក់ព័ន្ធទៅនឹងការដោះលែង/ការឃុំខ្លួនបណ្តោះអាសន្នទេ ហើយអាច រួមបង្កើតឱ្យមានវិធានការដែលនាំឱ្យមានការអូសបន្លាយ ។ អ.ប.ជ មិនផ្អាកដំណើរការនីតិវិធីណាមួយទេ នាពេលអនាគត បើសិន អ.ប.ជ សម្រេចថា សិទ្ធិរបស់ជនត្រូវចោទត្រូវបានគេរំលោភមែននោះ ស.ច.ស នឹងត្រូវអនុវត្តតាមសេចក្តីសម្រេចនោះជាបន្ទាន់ ។

(ង) ដើមបណ្តឹងឧទ្ធរណ៍ មិនបានបង្ហាញឱ្យឃើញអំពីស្ថានភាពផ្លាស់ប្តូរណាមួយ តាំងពី

[7] បណ្តឹងឧទ្ធរណ៍, C40/5/1, កថាខ័ណ្ឌទី៨៤-៨៥ ។

គាត់ត្រូវបានចាប់ឃុំខ្លួនពីដំបូង ដោយ ស.ច.ស នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ មក (“ដីកាសម្រេចឃុំខ្លួន”)[8] ។ នៅក្នុង ដីកាបដិសេធការដោះលែង ដោយបានធ្វើការវាយតម្លៃទៅលើភស្តុតាងនៅក្នុងសំណុំរឿងនោះ ស.ច.ស បានកត់សំគាល់ថា លក្ខខណ្ឌតម្រូវនៅក្រោមវិធាន ៦៣.៣.ក និងវិធាន៦៣.៣.ខ.១, វិធាន៦៣.៣.ខ.២, វិធាន៦៣.៣.ខ.៤, និង វិធាន ៦៣.៣.ខ.៥ នៅតែបានបំពេញទៅតាម ហើយ “ការឃុំខ្លួនបណ្តោះអាសន្ន”នៅតែជាវិធានការចាំបាច់មួយ បើផ្អែកទៅលើទឡ្ហីករណ៍ទាំងនោះ:”[9] ។

(ច) សំណុំរឿងនាពេលបច្ចុប្បន្ន មានភស្តុតាងដែលអាចបំពេញចំពោះអ្នកសង្កេតការណ៍ឯករាជ្យ នៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរនេះ ដែលថា ដើមបណ្តឹងឧទ្ធរណ៍អាចត្រូវបានប្រព្រឹត្តបទឧក្រិដ្ឋនានា ដែលនៅពេលបច្ចុប្បន្ននេះ គាត់កំពុងតែស្ថិតនៅក្រោមកិច្ចស៊ើបសួរ ។ ជាការបន្ថែម លក្ខខណ្ឌបែកចេញខុសៗគ្នាចំនួន៤ ក្នុងចំណោមលក្ខខណ្ឌទាំង៥ ដែលចាំបាច់សម្រាប់ការឃុំខ្លួន ក្រោមវិធាន៦៣.៣.ខ គឺមកទល់ពេលនេះនៅតែត្រូវបានបំពេញ ដើម្បីជាយុត្តិកម្ម សម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន ។ ជាពិសេស ការឃុំខ្លួនបណ្តោះអាសន្នដើមបណ្តឹងឧទ្ធរណ៍ គឺនៅតែជាវិធានការចាំបាច់មួយ ដើម្បី (១) ការពារសាក្សី និងជនរងគ្រោះ, (២) ដើម្បីថែរក្សាភស្តុតាង និងការពារមិនឲ្យបំផ្លាញភស្តុតាង, (៣) ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ និង (៤) ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ។

## ២. ប្រវត្តិនីតិវិធីពាក់ព័ន្ធ

៣. នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញា បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមួយ ដែលលំអិតអំពីអង្គហេតុនានា ព្រមទាំងបង្ហាញឈ្មោះដើមបណ្តឹងឧទ្ធរណ៍ និងជនសង្ស័យបួននាក់ផ្សេងទៀត ថាជាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋជាក់លាក់ ដែលស្ថិត

---

[8] *ករណីរបស់ ខៀវ សំផន,* ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ក.ស.ច, ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧, C26, ERN 00152991-96 (ភាសាបារាំង), 00156700-05 (ភាសាអង់គ្លេស) និង 00152973-78 (ភាសាខ្មែរ) [(*ចាប់ពីនេះតទៅហៅថា* ដីកាសម្រេចឃុំខ្លួន)] ។

[9] ដីកាបដិសេធការដោះលែង, C40/4, កថាខ័ណ្ឌទី ១១/២២ ។

00275473

C40/5/2



នៅក្នុងយុត្តាធិការរបស់តុលាការនេះ[10]។ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញា បានដាក់ "ឯកសារ និងប្រភពច្បាប់បន្ថែមដើម្បីគាំទ្រទៅលើទឡ្ហីករណ៍ សម្រាប់ការឃុំខ្លួនជនសង្ស័យជាបណ្ដោះអាសន្ន"[11] ។ ជនត្រូវចោទរូបនេះ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ និងបាននាំខ្លួនមកចំពោះមុខ ស.ច.ស ដើម្បីចូលបង្ហាញខ្លួនលើកដំបូង[12] និងសវនាការដេញដោលមួយ[13] ហើយត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩[14]។ ស.ច.ស បានចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ សម្រាប់រយៈពេលមិនលើសពីមួយឆ្នាំ ("ដីកាសម្រេចឃុំខ្លួន") នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧[15] ។ មេធាវីការពារក្ដី បានប្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចនេះ ដោយដាក់សារណាជាលាយលក្ខណ៍អក្សរមួយ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ ដោយផ្អែកទៅលើតែវិធាន៦៣.៣.ក ("វិធានផ្ទៃក្នុង") តែមួយប៉ុណ្ណោះ ។ សហព្រះរាជអាជ្ញា បានដាក់សារណាតបរបស់ខ្លួន ទៅនឹងបណ្ដឹងឧទ្ធរណ៍នេះ នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៨ និងដើមបណ្ដឹងរដ្ឋប្បវេណីដាក់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨[16] ។ អ.ប.ជ បានបើកសវនាការ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ ប៉ុន្តែបានពន្យារ

---

[10] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧, D3, ERN 00147244-7399 (ភាសាអង់គ្លេស), ERN 00197410-7545 (ភាសាបារាំង) និង ERN 00185898-6167 (ភាសាខ្មែរ) ។

[11] *ករណីរបស់ ខៀវ សំផន*, សេចក្ដីជូនដំណឹងអំពីការបង្ហាញឯកសារ និងប្រភពច្បាប់បន្ថែម ដើម្បីគាំទ្រទៅលើទឡ្ហីករណ៍ សម្រាប់ការឃុំខ្លួនជនសង្ស័យជាបណ្ដោះអាសន្ន, ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧, **D29** និង **D29/1**, ERN 00148902-04 និង 00148965-9841 (ភាសាអង់គ្លេស) ។ ការបង្ហាញជូននេះ ក៏មានរួមបញ្ចូលឯកសារអំពីអង្គហេតុចំនួន៣៣ច្បាប់ ដែលមានលក្ខណៈជាក់លាក់ចំពោះ ខៀវ សំផន នៅក្នុង **ឧបសម្ព័ន្ធ ក** ផងដែរ, ERN 00149340-566 (ភាសាអង់គ្លេស) ។

[12] *ករណីរបស់ ខៀវ សំផន*, កំណត់ហេតុនៃចូលបង្ហាញខ្លួនដំបូង, ស.ច.ស, ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧, **D42**, ERN 00153319-22 (ភាសាអង់គ្លេស), 00153333-36 (ភាសាបារាំង) និង 00153228-35 (ភាសាខ្មែរ) ។

[13] *ករណីរបស់ ខៀវ សំផន*, កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល, ស.ច.ស, ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧, **C25**, ERN 00153266-70 (ភាសាអង់គ្លេស), 00153296-301 (ភាសាបារាំង) និង 00153228-35 (ភាសាខ្មែរ) ។

[14] នៅថ្ងៃដដែលនេះដែរ សហព្រះរាជអាជ្ញាបានដាក់ទឡ្ហីករណ៍បន្ថែម ដើម្បីគាំទ្រដល់ការឃុំខ្លួនបណ្ដោះអាសន្នៈ ទឡ្ហីករណ៍បន្ថែមរបស់សហព្រះរាជអាជ្ញា ក្នុងការគាំទ្រការឃុំខ្លួនបណ្ដោះអាសន្នលើឈ្មោះ ខៀវ សំផន, ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧, **C28**, ERN 00153050-65 (ភាសាខ្មែរ), 00153041-49 (ភាសាអង់គ្លេស) និង 00161635-43 (ភាសាបារាំង) ។

[15] ដីកាសម្រេចឃុំខ្លួន, **C26** ។

[16] *ករណីរបស់ ខៀវ សំផន*, សារណាបណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧, សារណា ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧, **D26/I/3**, ERN 00158303-14 (ភាសាអង់គ្លេស); ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ដែលជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧, ចម្លើយតប

ពេលទៅវិញដោយសារតែ "មានផលវិបាក បណ្ដាលមកពីអាកប្បកិរិយារបស់មេធាវីការពារក្ដីអន្តរជាតិ" ដែលបានទទួលការព្រមានពី អ.ប.ជ ស្របតាមវិធាន៣៨[17] ។ មេធាវីការពារក្ដីបានដាក់ពាក្យសុំដោះលែងជាបណ្ដោះអាសន្នលើកទីមួយ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ដែលត្រូវបានបដិសេធ តាមរយៈដីកាសម្រេចរបស់ ស.ច.ស ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០០៨ ។ សេចក្ដីជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍ ត្រូវបានដាក់ដោយមេធាវីការពារក្ដី នៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៨[18] ប៉ុន្តែបណ្ដឹងឧទ្ធរណ៍នេះ ក៏ត្រូវបានច្រានចោលជាបន្តបន្ទាប់ ។ នៅថ្ងៃទី២២ ខែ កក្កដា ឆ្នាំ២០០៨ មេធាវីការពារក្ដីបានដាក់បណ្ដឹងឧទ្ធរណ៍មួយ នៅចំពោះមុខ អ.ប.ជ ប្រឆាំងនឹងដីកាសម្រេចស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ដែលត្រូវបានដាក់ឱ្យស្ថិតនៅក្នុងស្ថានភាពរង់ចាំ ("បណ្ដឹងឧទ្ធរណ៍ស្ដីពីការបកប្រែ")[19]៖ សវនាការជាសាធារណៈមួយ ត្រូវបានធ្វើឡើង នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨[20] ។ នៅថ្ងៃទី៨ ខែ

---

ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៨, D26/I/9, ERN 00160767-95 (ភាសាអង់គ្លេស); សេចក្ដីសន្និដ្ឋានរួមរបស់សហមេធាវីភាគីដើមបណ្ដឹងរដ្ឋប្បវេណី តបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨, **C26/I/21**, ERN 00178205-52 (ភាសាអង់គ្លេស) ។

[17] *ករណីរបស់ ខៀវ សំផន*, សេចក្ដីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់ អ.ប.ជ, ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨, **C26/I/26**, ERN 00180341-44 (ភាសាអង់គ្លេស); កំណត់ហេតុសវនាការរបស់ អ.ប.ជ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ លើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨, **C26/I/25**, ERN 00185534-41 (ភាសាអង់គ្លេស) ។

[18] *ករណីរបស់ ខៀវ សំផន*, ពាក្យបណ្ដឹងសុំដោះលែងលោក ខៀវ សំផន ឱ្យមានសេរីភាពបណ្ដោះអាសន្ន ដោយមូលហេតុសុខភាព, ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨, **C36**, ERN 00195934-35 (ភាសាអង់គ្លេស), 00195936-37 (ភាសាបារាំង) ។ សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញា លើសំណើរបស់មេធាវីការពារក្ដី សុំឱ្យដោះលែង ខៀវ សំផន ពីការឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨, **C36/II**, ERN 00196966-69; ដីកាសម្រេចបដិសេធសំណើសុំឱ្យដោះលែង របស់ ស.ច.ស, ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨, **C36/III**, ERN 00197169-73 (ភាសាបារាំង) និង 00198508-12 (ភាសាអង់គ្លេស); សៀវភៅចុះបណ្ដឹងឧទ្ធរណ៍ និងសេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍, ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨, **C36/III/1**, ERN 00198209-12 (ភាសាអង់គ្លេស) ។ ទឡ្ហីករណ៍នៃបណ្ដឹងឧទ្ធរណ៍ មិនធ្លាប់មានបានដាក់ទេ ។

[19] *ករណីរបស់ ខៀវ សំផន*, សារណាបណ្ដឹងឧទ្ធរណ៍របស់ក្រុមការពារក្ដី ចំពោះការបដិសេធសំណើសុំបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់លោកខៀវ សំផន, ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨, **A190/I/1**, ERN 00212334-52 (ភាសាអង់គ្លេស) និង ERN 00207411-29 (ភាសាបារាំង) [(*ចាប់ពីនេះតទៅហៅថា* បណ្ដឹងឧទ្ធរណ៍ស្ដីពីការបកប្រែ)] ។ ដីកាសម្រេចស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ, ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨, **A190**, ERN 00196923-30 (ភាសាអង់គ្លេស) [(*ចាប់ពីនេះតទៅហៅថា* ដីកាសម្រេចស្ដីពីសិទ្ធិនៃការបកប្រែ)] ។

[20] *ករណីរបស់ ខៀវ សំផន*, សេចក្ដីសម្រេចលើពាក្យសុំឱ្យមានសវនាការជាសាធារណៈ របស់លោក ខៀវ សំផន, ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨, **A/90/I/8**, ERN 00236251-54 (ភាសាអង់គ្លេស); ដីកាកែប្រែកាលបរិច្ឆេទសវនាការជាសាធារណៈ, ចុះថ្ងៃទី១៤ ខែ

00275475

C40/5/2



តុលា ឆ្នាំ២០០៨ មេធាវីការពារក្តីបានដកបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន[21] របស់ខ្លួនវិញហើយបានដាក់សំណើសុំដោះលែងជាបន្ទាន់មួយទៅ ស.ច.ស ស្របតាមវិធាន៦៤.២[22] ។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញា បានដាក់សារណាតបរបស់ខ្លួន ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសំណើរបស់ខៀវ សំផន សុំឱ្យមានការដោះលែងឱ្យមានសេរីភាពជាបន្ទាន់[23] ។ ស.ច.ស បានច្រានចោលសំណើសុំដោះលែងរបស់មេធាវីការពារក្តី ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០០៨ ដែលជាដីកាសម្រេចដែលត្រូវបានគេតវ៉ាដេញដោល ហើយមេធាវីការពារក្តីក៏បានដាក់ បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹង ដីកាបដិសេធការដោះលែង[24] នេះ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨[25] ។ ច្បាប់បកប្រែជាភាសាអង់គ្លេសនៃបណ្តឹងឧទ្ធរណ៍នេះ បានជូនដំណឹងដល់សហព្រះរាជអាជ្ញា នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩[26] ។

៤. ក្នុងគ្រានោះដែរ គឺត្រូវនឹងនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ អនុលោមតាមវិធាន៦៣.៧ នៃវិធានផ្ទៃក្នុង ស.ច.ស បានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីការពារក្តីរបស់ខ្លួនថា ស.ច.ស បាននឹងកំពុងពិចារណាបន្តថិរវេលានៃការឃុំខ្លួនជនត្រូវចោទនេះតទៅទៀត និងបានស្នើឱ្យបង្ហាញពីការកត់សំគាល់របស់ខ្លួន ក្នុងរយៈពេល១៥ ថ្ងៃ[27] ហើយមេធាវីការពារក្តី និង

---

វិច្ឆិកា ឆ្នាំ២០០៨, A/90/I/10, ERN 00238738-39 (ភាសាអង់គ្លេស); ប្រតិចារឹកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨, ERN 00251973-018 (ភាសាអង់គ្លេស), 00252019-67 (ភាសាបារាំង) និង 00252068-114 (ភាសាខ្មែរ) ។

[21] *ករណីរបស់ ខៀវ សំផន*, សេចក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍, ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨, C26/I/30, ERN 00228787-93 (ភាសាបារាំង), 00236251-54 (ភាសាអង់គ្លេស); សេចក្តីសម្រេចរបស់ អ.ប.ជ ពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍, ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៨, C26/I/31, ERN 00231971-74 (ភាសាអង់គ្លេស) ។

[22] សំណើសុំដោះលែងជាបន្ទាន់របស់មេធាវីការពារក្តី, C40 ។

[23] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសំណើរបស់ ខៀវ សំផន សុំឱ្យមានការដោះលែងឱ្យមានសេរីភាពជាបន្ទាន់, ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៨, C40/3, ERN 00234631-45 (ភាសាអង់គ្លេស) [(*ចាប់ពីនេះតទៅហៅថា* ចម្លើយតបរបស់ក.ស.ព ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ)] ។

[24] ដីកាបដិសេធការដោះលែង, C40/4 ។

[25] បណ្តឹងឧទ្ធរណ៍, C40/5/1 ។

[26] បណ្តឹងឧទ្ធរណ៍, C40/5/1, ERN 00269865-82 (ភាសាអង់គ្លេស) ។

[27] *ករណីរបស់ ខៀវ សំផន*, សេចក្តីជូនដំណឹងរបស់ ស.ច.ស ស្របតាមវិធាន៦៣.៧ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨, C26/2, ERN 00235400-01 (ភាសាបារាំង) ។

ជនត្រូវចោទក៏បានដាក់ដូច្នេះមែន នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨[28] ។ ស.ច.ស បានចេញដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន របស់ខ្លួន ("ដីកាសម្រេចបន្តការឃុំខ្លួន") នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨[29] ហើយមេធាវីការពារក្តីក៏បានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួននៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨[30] ។ សហព្រះរាជអាជ្ញា បានដាក់សារណាតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះ នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩ នេះ[31] ។

៥. ជាចុងក្រោយ នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ ជនត្រូវចោទបានដាក់សំណើជាយថាហេតុ និងបន្ទាន់បំផុត ដើម្បីស្នើសុំឱ្យមានការដោះលែងឱ្យមានសេរីភាព នៅចំពោះមុខ អ.ប.ជ[32] ដែលត្រូវបដិសេធថា មិនអាចទទួលយកបានឡើយ ដោយប្រធាន អ.ប.ជ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨[33] ។

## ៣. សេចក្តីសន្និដ្ឋានបឋម

***សវនាការផ្ទាល់មាត់មិនចាំបាច់ទេ***

---

[28] *ករណីរបស់ ខៀវ សំផន*, សេចក្តីជំទាស់របស់ក្រុមការពារក្តី ទាក់ទងនឹងការបន្តការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨, C26/3, ERN 00238930-41 (ភាសាបារាំង), ERN 00238914-23 (ភាសាខ្មែរ) ។ សម្រាប់ភាសាអង់គ្លេស នៅមិនទាន់មាននៅឡើយរហូតមកដល់ពេលនេះ ។

[29] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨, C26/4, ERN 00250773-81 (ភាសាអង់គ្លេស) [(*ចាប់ពីនេះតទៅហៅថា* ដីកាសម្រេចបន្តការឃុំខ្លួន)] ។

[30] *ករណីរបស់ ខៀវ សំផន*, សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨, C26/5/1, ERN 00251782-98 (ភាសាអង់គ្លេស) ។

[31] *ករណីរបស់ ខៀវ សំផន*, ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨, ចម្លើយតបចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩, C26/5/10, ERN 00270279-97 (ភាសាអង់គ្លេស) និង 00270298-326 (ភាសាខ្មែរ) ។

[32] *ករណីរបស់ ខៀវ សំផន*, សំណើជាយថាហេតុ និងបន្ទាន់បំផុតដើម្បីស្នើសុំឱ្យមានការដោះលែងឱ្យមានសេរីភាព, ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨, C26/5/2, ERN 00249810-14 (ភាសាបារាំង), 00250603-07 (ភាសាអង់គ្លេស) និង 00249810-14 (ភាសាខ្មែរ); ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើជាយថាហេតុ និងបន្ទាន់បំផុតដើម្បីស្នើសុំឱ្យមានការដោះលែងឱ្យមានសេរីភាព, ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៨, C26/5/4, ERN 00250974-80 (ភាសាអង់គ្លេស), 00250981-91 (ភាសាខ្មែរ) ។

[33] សេចក្តីសម្រេចរបស់ អ.ប.ជ លើសំណើជាយថាហេតុរបស់លោកខៀវ សំផន សុំដោះលែងឱ្យមានសេរីភាព, , C26/5/5, ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨, ERN 00251469-74 (ភាសាអង់គ្លេស) ។

៦. វិធាន៧៧.៣.ខ នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះ កំណត់សម្រេចលើបណ្តឹងឧទ្ធរណ៍ណាមួយ តែនៅលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែរបស់ភាគីប៉ុណ្ណោះ បន្ទាប់ពីមានការពិចារណាទៅលើទស្សនៈផ្សេងៗរបស់ភាគីរួចមក ។ ដើមបណ្តឹងឧទ្ធរណ៍មិនបានសុំឱ្យមានសវនាការផ្ទាល់មាត់ណាមួយទេ ចំពោះបណ្តឹងឧទ្ធរណ៍នេះ ។ បណ្តឹងឧទ្ធរណ៍នេះ មិនបានលើកឡើងពីអំណះអំណាងខាងផ្នែកអង្គហេតុ ឬ អង្គច្បាប់ថ្មី ដែលចាំបាច់ត្រូវឱ្យមាន សវនាការផ្ទាល់មាត់ណាមួយនោះឡើយ ។ បញ្ហាស្តីពីសិទ្ធិនៃការបកប្រែ ដែលជារឿងនៅពីខាងក្រោយបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានលើកយកមកជជែកវែកញែកជាសាធារណៈរួចហើយ នៅ ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ ។ ដើម្បីប្រយោជន៍ផ្នែកសេដ្ឋកិច្ចរបស់តុលាការ សហព្រះរាជអាជ្ញា សូមស្នើឱ្យ អ.ប.ជ ធ្វើការកំណត់សម្រេចនៅលើបណ្តឹងនេះ តែចំពោះសេចក្តីផ្លានជាលាយលក្ខណ៍អក្សរតែមួយមុខគត់ប៉ុណ្ណោះ ។

## ៤. អង្គច្បាប់

### *ក. បន្ទុកនៃភស្តុតាង*

៧. មេធាវីការពារក្តីនិយាយថា "ជាគោលការណ៍ ជនត្រូវចោទ ត្រូវតែមានសេរីភាព" ការឃុំខ្លួនបណ្តោះអាសន្ន កំពុងត្រូវបានស្ថិតនៅជាអញ្ញត្រកម្ម ។ សេចក្តីថ្លែងនេះ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និង តាមការសន្មតដែលថា សច្ចធារណ៍នេះ ជាទូទៅត្រូវបានគេពិចារណាដោយសម័យប្រជុំពេញអង្គដើម្បីឱ្យមានភាពជាក់ស្តែង ហេតុដូច្នេះ មេធាវីការពារក្តីសន្និដ្ឋានថា វាជាការឥតប្រយោជន៍ដែលត្រូវដាក់បញ្ចូលនៅក្នុងវិធាន អ.វ.ត.ក[34] ។ មេធាវីការពារក្តីតវ៉ាថា ស.ច.ស ខកខានមិនបានផ្តល់យុត្តិកម្មចំពោះសេចក្តីសម្រេចរបស់ខ្លួនទេ ទាក់ទងនឹងស្ថានការណ៍ទាំងមូលនៃករណីនេះ ដែលថាដីកាសម្រេចរបស់ស.ច.ស បានពឹងផ្អែកទៅលើតែភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋតែប៉ុណ្ណោះ និងថា ស.ច.ស មិនបានបង្ហាញភស្តុតាងអំពីអត្ថិភាពនៃហានិភ័យណាមួយនៅក្នុងវិធាន ៦៣.៣.ខ.១, វិធាន ៦៣.៣.ខ.៤ និង វិធាន ៦៣.៣.ខ.៥ នោះឡើយ[35] ។

---

[34] បណ្តឹងឧទ្ធរណ៍, C40/5/1, កថាខ័ណ្ឌទី២៤, កំណត់សំគាល់ចុងទំព័រលេខ២១ ។

[35] បណ្តឹងឧទ្ធរណ៍, C40/5/1, កថាខ័ណ្ឌទី៣, ២៤-៣៣, ៣៤-៤២, ៤៥ និង៤៦-៨០ ។

៨. ដូចបានបញ្ជាក់នៅក្នុងសេចក្ដីសន្និដ្ឋានមុនៗ[36] គេមិនមានគោលការណ៍ណែនាំជាក់លាក់ នៅក្នុងវិធាន ឬនៅក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា ស្ដីពីបន្ទុកនៃភស្តុតាងនៅក្នុងសវនាការឃុំខ្លួនទេ ។ ប៉ុន្ដែ សំណើសុំដោះលែងជាបណ្ដោះអាសន្ន ដែលបានផ្អែកលើវិធាន៦៤.២ ដូចជាសំណើសុំរបស់មេធាវីការពារក្ដីមួយនេះជាដើម ត្រូវតែបានបែងចែកឲ្យខុសគ្នា អំពីការត្រួតពិនិត្យទៀងទាត់ខាងមិនបាននៅលើលក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន (វិធាន៦៣.៦ និងវិធាន៦៣.៧) និងលទ្ធភាពដែលថា ស.ច.ស អាចដោះលែងជនត្រូវចោទនៅពេលណាមួយក៏បាន ប្រសិនបើលក្ខខណ្ឌតម្រូវនៃការឃុំខ្លួនបណ្ដោះអាសន្ន លែងមានទៀតហើយ (វិធាន៦៤.១) ។ នៅក្នុងក្របខ័ណ្ឌនៃបណ្ដឹងឧទ្ធរណ៍ មេធាវីការពារក្ដី ចាំបាច់ត្រូវតែបង្កើតឲ្យមានធាតុផ្សំជាក់ស្ដែង ដើម្បីជាយុត្តិកម្មសម្រាប់ការដោះលែងជនត្រូវចោទ ប៉ុន្ដែមេធាវីខកខានមិនបានធ្វើដូច្នេះទេ ។ គោលការណ៍ណែនាំអាចនឹងរកបានផងដែរ នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្ដរជាតិ ដែលតាមការអនុវត្តន៍ជាក់ស្ដែងគឺថា នៅពេលណាជនសង្ស័យត្រូវបានដាក់ឲ្យជាប់ឃុំឃាំងបណ្ដោះអាសន្ន បន្ទុកនៃភស្តុតាងត្រូវធ្លាក់ទៅលើមេធាវីការពារក្ដី[37] ដើម្បីបំពេញលក្ខខណ្ឌនានាដល់តុលាការ

---

[36] ឧទាហរណ៍ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, C40/3, កថាខ័ណ្ឌទី៨-១០ ។

[37] *រដ្ឋអាជ្ញា ទល់នឹង Haradinaj* សេចក្ដីសម្រេចលើញត្តិស្នើសុំឲ្យដោះលែងជាបណ្ដោះអាសន្នរបស់ Ramush Haradinaj សំណុំរឿងលេខ IT-04-84-PT, អង្គជំនុំជម្រះសាលាដំបូង ICTY, ចុះថ្ងៃទី០៦ មិថុនា ២០០៥, កថាខណ្ឌទី២១ (C11/11, ប្រភពច្បាប់ C24); *រដ្ឋអាជ្ញា ទល់នឹង Prlic និងគូកន,* សេចក្ដីសំរេចលើញត្តិស្នើសុំឲ្យពិនិត្យពិចារណាឡើងវិញ បញ្ជាក់បំភ្លឺលើ សំណើសុំដោះលែង និងសំណើសុំប្ដឹងឧទ្ធរណ៍, សំណុំរឿងលេខ IT-04-74-AR65, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ចុះថ្ងៃទី០៨ កញ្ញា ឆ្នាំ២០០៤, កថាខណ្ឌទី២៨ (C11/11, ប្រភពច្បាប់ C37); *រដ្ឋអាជ្ញា ទល់នឹង Sesay និងគូកន,* សេចក្ដីសម្រេចលើញត្តិ ដាក់ជូនដោយ Morris Kallon ដែលស្នើសុំឲ្យដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ, សំណុំរឿងលេខ SCSL-04-15-PT, អង្គជំនុំជម្រះសាលាដំបូង SCSL, ចុះថ្ងៃទី២៣ កុម្ភៈ ២០០៤, (C11/11, ប្រភពច្បាប់ C42), កថាខណ្ឌទី២៩ (បញ្ជាក់ថា "ទោះជាយ៉ាងណាក៏ដោយ វាហាក់ដូចជាថា តាមរយៈករណីយុត្តិសាស្ត្រភាគច្រើនបំផុតរបស់ ICTY និង ICTR បង្ហាញឲ្យឃើញថា តាមរយៈដំណើរការប្រកបដោយការថ្លឹងថ្លែងទៅលើសេចក្ដីសន្និដ្ឋានរបស់ភាគីទាំងពីរ បន្ទុកនៃភស្តុតាងនៅតែធ្លាក់ទៅលើមេធាវីការពារក្ដីដដែល គឺមិនមែនធ្លាក់ទៅលើអយ្យការទេ"); *រដ្ឋអាជ្ញា ទល់នឹង Issa Hassan Sesay,* សេចក្ដីសំរេចលើពាក្យសុំឲ្យដោះលែងជាបណ្ដោះអាសន្នរបស់ Issa Sesay, សំណុំរឿងលេខ SCSL-04-15-PT, អង្គជំនុំជម្រះសាលាដំបូង SCSL, ចុះថ្ងៃទី៣១ មីនា ២០០៤, កថាខណ្ឌទី៣៧ (C11/11, ប្រភពច្បាប់ C40); *រដ្ឋអាជ្ញា ទល់នឹង Fatmir Limaj និងគូកន,* សេចក្ដីសម្រេចលើសំណើសុំឲ្យដោះលែងជាបណ្ដោះអាសន្នរបស់ Fatmir Limaj, សំណុំរឿងលេខ IT-03-66-AR65, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ចុះថ្ងៃទី៣១ តុលា ២០០៣, កថាខណ្ឌទី៤០ (C11/11, ប្រភពច្បាប់ C27); *រដ្ឋអាជ្ញា ទល់នឹង Rahim Ademi,* សេចក្ដីសម្រេចលើញត្តិស្នើសុំឲ្យដោះលែងជាបណ្ដោះអាសន្ន, សំណុំរឿងលេខ IT-01-46-PT, អង្គជំនុំជម្រះសាលាដំបូង ICTY, ចុះថ្ងៃទី២០ កុម្ភៈ ២០០២, (C20/I/7, ប្រភពច្បាប់ B33), កថាខ័ណ្ឌទី១៩; *រដ្ឋអាជ្ញា ទល់នឹង Brdjanin និង Talic,* សេចក្ដីសំរេចលើញត្តិស្នើសុំឲ្យដោះលែងជាបណ្ដោះអាសន្នរបស់ Momir

ជាយុត្តិកម្មដើម្បីទទួលបាន "ការដោះលែងជាបណ្ដោះអាសន្ន"[38] ។ លើសពីនេះទៀត តុលាការអន្តរជាតិ និងតុលាការដែលធ្វើទៅជាលក្ខណៈអន្តរជាតិនានា បានចាត់ទុកការដោះលែងបណ្ដោះអាសន្ន ថាជាការលើកលែង ជាជាងតាមគោលការណ៍កំណត់[39] ។ ចៅក្រម

---

Talic, សំណុំរឿងលេខ IT-99-36-T, អង្គជំនុំជម្រះសាលាដំបូង ICTY, ចុះថ្ងៃទី២៨ មីនា ឆ្នាំ២០០១, កថាខណ្ឌទី១៧–១៨ (C11/11, ប្រភពច្បាប់ C16) ។

[38] នៅតុលាការ ICTY, ICTR និង SCSL, ការបង្គាប់ឲ្យដោះលែងអាចនឹងត្រូវបានធ្វើឡើង ប្រសិនបើតុលាការត្រូវបានគេបង្ហាញឲ្យឃើញនិងជឿជាក់ថា ជនសង្ស័យនឹងត្រូវចូលខ្លួននៅពេលសវនាការ និងថា ប្រសិនបើត្រូវបានដោះលែង ជនសង្ស័យនឹងមិនធ្វើឲ្យមានការគ្រោះថ្នាក់ដល់ជនរងគ្រោះ សាក្សី អ្នកដទៃទៀតណាម្នាក់ឡើយ ។ សូមអាន: វិធាន ៦៥ នៃវិធានស្ដីពីនីតិវិធី និងភស្តុតាង របស់ ICTY, (C11/11, ប្រភពច្បាប់ C10), វិធានស្ដីពីនីតិវិធី និងភស្តុតាង របស់ ICTR, (C11/11, ប្រភពច្បាប់ C8), និង វិធានស្ដីពីនីតិវិធី និងភស្តុតាង របស់ SCSL, (C11/11, ប្រភពច្បាប់ C11); *រដ្ឋអាជ្ញា ទល់នឹង Lukic,* សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ មេធាវីការពារក្ដី ដែលជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើញត្តិស្នើសុំឲ្យដោះលែងជាបណ្ដោះអាសន្ន Sredoje Lukic, សំណុំរឿងលេខ IT-98-32/1-AR65.1, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ចុះថ្ងៃទី១៦ មេសា ២០០៧, កថាខណ្ឌទី៧ (C40/5/1, ប្រភពច្បាប់ C1) ។

[39] **ឧទាហរណ៍មួយចំនួននៃការបដិសេធនៅចំពោះមុខតុលាការ ICTY៖** *Prosecutor v. Darko Mrdja* សេចក្ដីសំរេចលើសំណើសុំឱ្យដោះលែងបណ្ដោះអាសន្នរបស់ Darko Mrdja, សំណុំរឿងលេខ IT-02-59-P, អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY, ចុះថ្ងៃទី១៥ មេសា ២០០២, កថាខណ្ឌទី២៩ (C11/11, ប្រភពច្បាប់ C19); *Prosecutor v. Mile Mrksic,* សេចក្ដីសំរេចលើបណ្ដឹងឧទ្ធរណ៍ដែលតវ៉ាប្រឆាំងនឹងការបដិសេធន៍មិនព្រមអនុញ្ញាតឲ្យដោះលែងបណ្ដោះអាសន្ន, សំណុំរឿងលេខ IT-95-13/1-AR65, អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់ ICTY, ចុះថ្ងៃទី០៨ តុលា ២០០២, (C11/11, ប្រភពច្បាប់ C31); *Prosecutor v. Pasko Ljubicic,* សេចក្ដីសំរេចលើញត្តិរបស់មេធាវីការពារក្ដីស្នើសុំឲ្យដោះលែងជនជាប់ចោទជាបណ្ដោះអាសន្ន, សំណុំរឿងលេខ IT-00-41-PT, អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY, ចុះថ្ងៃទី០២ សីហា ២០០២, (C11/11, ប្រភពច្បាប់ C35); *Prosecutor v. Limaj et al,* សេចក្ដីសំរេចលើការដោះលែងជាបណ្ដោះអាសន្នរបស់ Fatmir Limaj, សំណុំរឿងលេខ IT-03-66-PT, អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY, ចុះថ្ងៃទី១២ កញ្ញា ២០០៣, (C11/11, ប្រភពច្បាប់ C26); ដែលបានបញ្ជាក់អះអាងដោយ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៅក្នុងករណី *Prosecutor v. Fatmir Limaj et al.,* សេចក្ដីសំរេចលើសំណើរបស់ *Fatmir Limaj* សុំឲ្យមានការដោះលែងបណ្ដោះអាសន្ន, សំណុំរឿងលេខ IT-03-66-AR65, អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់ ICTY, ចុះថ្ងៃទី៣១ តុលា ២០០៣ កថាខណ្ឌទី៤០ (C11/11, ប្រភពច្បាប់ C27) ។ មានតែប្រហែលប្រាំបីភាគរយប៉ុណ្ណោះនៃជនជាប់ឃុំខ្លួននៅ ICTY បានទទួលអត្ថប្រយោជន៍ពីការដោះលែងជាបណ្ដោះអាសន្ន ។ ក្នុងចំណោមពួកគេ គឺជាជនដែលគេសង្ស័យថាជាប់ពាក់ព័ន្ធនឹងបទល្មើសមិនសូវធ្ងន់ធ្ងរ អ្នកដែលបានចុះចូលដោយស្ម័គ្រចិត្ត និងអ្នកដែលបានសហការយ៉ាងពេញលេញជាមួយ ICTY (ដូចជា Ademi), អ្នកដែលមានផ្ទុកជម្ងឺមិនអាចព្យាបាលបាន (ដូចជា Talic) ឬ អ្នកដែលត្រូវទទួលបាននូវការធានាពីរដ្ឋ ចំពោះវិធានការសន្តិសុខពិសេស ។ **ករណីនានានៅតុលាការ SCSL៖** *Prosecutor v. Sesay et al.,* សេចក្ដីសំរេចលើញត្តិស្នើសុំឲ្យដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ធ្វើឡើងដោយ Morris Kallon, សំណុំរឿងលេខ SCSL-04-15-PT, អង្គជំនុំជម្រះសាលាដំបូងរបស់ SCSL, ចុះថ្ងៃទី២៣ កុម្ភៈ ២០០៤, កថាខណ្ឌទី៣៥ (C11/11, ប្រភពច្បាប់ C42); *Prosecutor v. Sam Hinga Norman,* សេចក្ដីសំរេចលើញត្តិស្នើសុំឲ្យធ្វើការកែប្រែលក្ខខណ្ឌនៃការឃុំឃាំង, សំណុំរឿងលេខ SCSL-2003-08-PT, ប្រធានតុលាការ SCSL, ចុះថ្ងៃទី២៦ វិច្ឆិកា ២០០៣, កថាខណ្ឌទី៨ (C11/11, ប្រភពច្បាប់ C41) ។ <u>ការដោះលែងបណ្ដោះអាសន្នមិនធ្លាប់ត្រូវបានអនុញ្ញាតឡើយ នៅតុលាការពិសេសសម្រាប់ប្រទេស</u>

00275480

C40/5/2



Geoffrey Robertson, ប្រធានតុលាការពិសេសនៃប្រទេសសៀរ៉ាឡេអូន បានបញ្ជាក់យ៉ាងច្បាស់ថា "គ្មានសច្ចធារណ៍សម្រាប់ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការឡើយ ដែលនេះអាចឱ្យយល់បានថា ដោយសារតែប្រភេទនៃបទល្មើសដែលបានចោទប្រកាន់នោះឯង"[40] ។

៩. ទោះបីគេតែងតែត្រូវធ្វើឱ្យមានតុល្យការជាមួយនឹងសិទ្ធិរបស់ជនជាប់ចោទក៏ដោយ[41] ក៏កត្តានេះ មានលក្ខណៈខុសប្លែកយ៉ាងពិសេសចំពោះសាលាក្តីនានា ដែលដោះស្រាយជាមួយនឹងបទឧក្រិដ្ឋ ដែលជាកង្វល់ជាអន្តរជាតិបែបនេះ ដូចដែលបានទទួលស្គាល់នៅតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន នៅក្នុងករណីរឿង *រដ្ឋអាជ្ញា ទល់នឹង Issa Hasan Sesay.*[42] តាមអំណះអំណាងដូចបានពោលខាងលើ សហព្រះរាជអាជ្ញាសន្និដ្ឋានថា នេះគឺជាបន្ទុកនៃភស្តុតាងរបស់ជនត្រូវចោទ ដើម្បីបង្ហាញឱ្យឃើញថា កត្តានានាដើម្បីជាយុត្តិកម្មសម្រាប់ការដោះលែងជាបណ្តោះអាសន្ន មិនមានទៀតទេ ។ អាស្រ័យហេតុនេះ មេធាវីការពារក្តីមិនអាចប្រើប្រាស់បណ្តឹងឧទ្ធរណ៍នេះ ធ្វើជាការផ្ទេរបន្ទុកនៃភស្តុតាងមកឱ្យ ស.ច.ស តាមការតវ៉ាថា ស.ច.ស ខកខានមិនបានបង្ហាញភស្តុតាងឱ្យឃើញថា លក្ខខណ្ឌតម្រូវនៃវិធាន៦៣.៣.ខ ត្រូវបានបំពេញនោះឡើយ ។

---

<u>សៀរ៉ាឡេអូន</u> ។ សូមអាន: Archbold, *តុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍៖ ការអនុវត្តន៍ នីតិវិធី និងភស្តុតាង* (ទីក្រុងឡុងដ៏៖ Sweet and Maxwell ឆ្នាំ2005), វាក្យខ័ណ្ឌទី ៧-១២៩, ទំព័រទី២៨៤ និង វាក្យខ័ណ្ឌទី៧-១៣២, ទំព័រទី២៨៥ (C11/11, ប្រភពច្បាប់ C43) ។ ជាការបន្ថែម <u>ការដោះលែងបណ្តោះអាសន្ន ពិតជាកម្រត្រូវបានអនុញ្ញាតដោយតុលាការ ICTR ណាស់</u> ។

[40] *Prosecutor v. Sam Hinga Norman,* សេចក្តីសំរេចលើញត្តិស្នើសុំឱ្យធ្វើការកែប្រែលក្ខខណ្ឌនៃការឃុំឃាំង, សំណុំរឿងលេខ SCSL-2003-08-PT, ប្រធានតុលាការ SCSL, ចុះថ្ងៃទី២៦ វិច្ឆិកា ២០០៣, កថាខណ្ឌទី៨ (C11/11, ប្រភពច្បាប់ C41) ។

[41] *Prosecutor v. Dragan Nicolic,* សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ស្តីពីបញ្ហាបន្ទាន់បង្ខំ ទាក់ទិននឹងនីត្យានុកូលភាពនៃការចាប់ខ្លួន, សំណុំរឿងលេខ IT-94-2-AR73, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី០៥ មិថុនា ២០០៣, កថាខណ្ឌទី៣០.៥ (C11/11, ប្រភពច្បាប់ C22) ។

[42] *Prosecutor v. Issa Hasan Sesay,* សេចក្តីសំរេចលើពាក្យសុំឱ្យដោះលែងជាបណ្តោះអាសន្នរបស់ Issa Sesay, សំណុំរឿងលេខ SCSL-04-15-PT, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ SCSL, ចុះថ្ងៃទី៣១ មីនា ២០០៤, កថាខណ្ឌទី៤០ (C11/11, ប្រភពច្បាប់ C40) ដែលនៅក្នុងនោះ តុលាការបានសម្រេចថា: "... គេត្រូវចាំទុកក្នុងចិត្តថា ដោយសារចរិតធម្មជាតិជាក់លាក់របស់សាលាក្តីនានា បទឧក្រិដ្ឋទាំងឡាយដែលសាលាក្តីទាំងនេះមានយុត្តាធិការទៅលើ អាចនឹងត្រូវបានគេចាត់ជាជំពូកថា ជាបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុតនៅក្រោមច្បាប់អន្តរជាតិ ។ អាស្រ័យហេតុនេះ គេអាចនិយាយបានថា យុទ្ធវិធីដើម្បីដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលមានលក្ខណៈលុបលើច្បាប់នីតិសាមញ្ញនៃតុលាការជាតិ អាចនឹងខុសគ្នាពីតុលាការអន្តរជាតិ" ។

00275481

C40/5/2



## *ភារកិច្ចក្នុងការផ្ដល់សំអាងហេតុនៅក្នុងដីកាសម្រេចនៃការឃុំខ្លួន*

១០. មេធាវីការពារក្ដីឱ្យដឹងថា សេចក្ដីសម្រេចដែលបានតវ៉ានេះ មិនមានយុត្តិកម្ម ឬ មតិសមហេតុផលទេ ដោយសារស.ច.ស មិនបានគិតគូរអំពីស្ថានភាពទាំងមូលនៃករណី ហើយសេចក្ដីសម្រេច នេះពឹងផ្អែកទៅលើតែភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់តែប៉ុណ្ណោះ ។ យោងតាម មេធាវីការពារក្ដី ដូច្នេះ ការឃុំខ្លួន គឺមានបំណងធ្វើជានិមិត្តរូបសុទ្ធសាធ និងឈរលើវិធានការខុសច្បាប់[43] ។ សហព្រះរាជអាជ្ញាយល់អំពីការផ្ដល់ហេតុផលរបស់គេ ដូចបានយោងទៅលើនីតិវិធីដែលមិនទាន់បានសម្រេចនៅឡើយ ស្ដីពីសិទ្ធិនៃការបកប្រែនៅចំពោះមុខ អ.ប.ជ និង ការរំលោភសិទ្ធិដែលបានចោទឡើងដោយមេធាវីការពារក្ដី ដែលថាមិនអាចឱ្យគេធ្វើការការពារក្ដីដោយប្រសិទ្ធភាព ដែលលើកស្នួយដោយមេធាវីការពារក្ដីនោះ[44] ។

១១. វិធាន៦៤.២ តម្រូវឱ្យសហចៅក្រមស៊ើបអង្កេត ត្រូវមានសំអាងហេតុ ចំពោះសេចក្ដីសម្រេចនៅលើសំណើសុំឱ្យមានការដោះលែង ។ សំអាងហេតុទាំងនេះ ត្រូវតែផ្ដល់ក្រោយពីមានការពិចារណាទៅលើសំណើសុំ សំណុំរឿង និងមតិយោបល់របស់សហព្រះរាជអាជ្ញារួចមក ។ ដោយបានយោងលើករណីយុត្តិសាស្ត្រអន្តរជាតិដែលបានទទួលស្គាល់ អ.ប.ជ បានរកឃើញថា សេចក្ដីសម្រេចទាំងអស់របស់អង្គតុលាការ រួមទាំងរបស់ ស.ច.ស ផង ត្រូវតែ ផ្ដល់សំអាងហេតុ ដើម្បីតម្រូវតាមបទដ្ឋានអន្តរជាតិ[45] ។ អ.ប.ជ បានកំណត់ថា កាតព្វកិច្ចក្នុងការផ្ដល់មូលហេតុ គ្រាន់តែតម្រូវថា ស.ច.ស បង្ហាញអង្គច្បាប់ និងអង្គហេតុដែលត្រូវបានយកមកពិចារណាមុនពេលចេញសេចក្ដីសម្រេច ។ ស.ច.ស អាចអនុវត្តកាតព្វកិច្ចនេះ "ដោយយោងលើសំណុំរឿង ក្នុងកាលៈទេសៈទូទៅ និងកាលៈទេសៈដទៃទៀត" ដោយសារ ស.ច.ស មិនមានកាតព្វកិច្ចផ្ដល់ការយល់ឃើញរបស់ខ្លួនលើកត្តាទាំងអស់ឡើយ ប៉ុន្តែមិនទៅ

---

[43] បណ្ដឹងឧទ្ធរណ៍, C40/5/1, កថាខ័ណ្ឌទី១០, និង២៣-៣៣ ។

[44] មេធាវីការពារក្ដីអះអាងថា ខ្លួនមិនទទួលបានលទ្ធភាពចូលមើលសំណុំរឿង ក្នុងភាសាមួយដែលសហមេធាវីអន្តរជាតិអាចយល់បានទេ។ សូមបណ្ដឹងឧទ្ធរណ៍, C40/5/1, កថាខ័ណ្ឌទី៨, ២៨, ៣០-៣៣ ។

[45] *ករណីរបស់ នួន ជា*, សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព, ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨, D55/I/8, ERN 00129322-33 (ភាសាអង់គ្លេស), កថាខ័ណ្ឌទី២១ [(*ចាប់ពីនេះតទៅហៅថា* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន នួន ជា)] ។

លើតែកត្តាដែលពាក់ព័ន្ធមួយប៉ុណ្ណោះទេ[46] ។ ការពិត ដីកាបដិសេធការដោះលែង បានផ្តល់មូលហេតុគ្រប់គ្រាន់ និងសមល្មមហើយ ។

១២. ពាក់ព័ន្ធនឹងបញ្ហាស្តីពី សិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងការបកប្រែ ដែលកំពុងព្យួរនៅចំពោះមុខ អ.ប.ជ[47] ដែលត្រូវបានលើកឡើងជាបន្តបន្ទាប់ពីសំណាក់មេធាវីការពារក្តី នៅក្នុងបណ្តឹងឧទ្ធរណ៍[48] នោះវាមិនទាក់ទងដោយចំពោះទៅនឹងនីត្យានុកូលភាពនៃការឃុំខ្លួនបណ្តោះអាសន្ននោះទេ ។ អ.ប.ជ បានសម្រេចថាខ្លួនអាចចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទដែលជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន បានមុនចេញសេចក្តីសម្រេចលើបញ្ហាដាច់ដោយឡែកទាក់ទងនឹងការបកប្រែ[49] ។ ផ្ទុយទៅនឹងការប៉ុនប៉ងរបស់មេធាវីការពារក្តី ក្នុងការដាក់បញ្ហាទាំងពីរនេះបញ្ចូលគ្នា ស.ច.ស ក៏បានបង្ហាញផងដែរថាបញ្ហាទាំងពីរនេះ គឺ ខុស

---

[46] *ករណីរបស់ អៀង សារី,* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន របស់ អ.ប.ជ, ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨, C22/I/74, ERN 00232976-004 (ភាសាអង់គ្លេស), កថាខណ្ឌទី៦៤-៦៦ [(*ចាប់ពីនេះតទៅហៅថា* សាលដីកាលើបណ្តឹងឧទ្ធរណ៍ អៀង សារី)] ។ សូមអានផងដែរ ករណីយុត្តិសាស្ត្ររបស់ ICTY: *រដ្ឋអាជ្ញា ទល់នឹង Popovic និងគូកន,* សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ស្តីពីបញ្ហាអញ្ញត្រកម្ម របស់អង្គជំនុំជម្រះសាលាដំបូង សំរេចបដិសេធការដោះលែងបណ្តោះអាសន្នលើ Ljubomir Borovcanin, សំណុំរឿងលេខ IT-05-88-AR65, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១ មីនា ២០០៧, កថាខ័ណ្ឌទី៧ (C9/4/2, ប្រភពច្បាប់ C9) ។ *រដ្ឋអាជ្ញា ទល់នឹង Haradinaj,* សេចក្តីសម្រេចលើញត្តិស្នើសុំឱ្យដោះ លែង ជាបណ្តោះអាសន្នលើ Lati Brahimaj សំណុំរឿងលេខ IT-04-84-PT, អង្គជំនុំជម្រះសាលាដំបូង ICTY, ចុះថ្ងៃទី០៣ ឧសភា ២០០៦, កថាខណ្ឌទី១៦ ។ *រដ្ឋអាជ្ញា ទល់នឹង Lukic,* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីដែល ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើញត្តិស្នើសុំឱ្យដោះលែងជាបណ្តោះអាសន្ន Sredoje Lukic, សំណុំរឿងលេខ IT-98-32/1-AR65.1, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ចុះថ្ងៃទី១៦ មេសា ២០០៧, កថាខណ្ឌទី៧ (C40/5/1, ប្រភពច្បាប់ C1) ដែលនៅ ក្នុងនោះ ង្គជំនុំជម្រះសាលា ឧទ្ធរណ៍បានបញ្ជាក់ថា "ក្នុងការសម្រេចថាតើ លក្ខខណ្ឌនានានៅក្រោមវិធាន៦៥.ខ នៃវិធានផ្ទៃក្នុង បានបំពេញតាមដែរឬទេនោះ, ជាអ្វី ដែលអង្គជំនុំជម្រះសាលាដំបូងប្រកបដោយ ហេតុផលមួយត្រូវបានគេរំពឹងទុកថា នឹងយកមកគិតគូរមុននឹងធ្វើសេចក្តីសម្រេច ។ បន្ទាប់ មក ត្រូវមានមតិយោបល់ដែលមានមូលហេតុបង្ហាញពីទស្សនៈរបស់ខ្លួននៅលើកត្តាដែលពាក់ព័ន្ធទាំងអស់នោះ [...] ។ មិនថាកត្តាដែលពាក់ព័ន្ធនោះជាអ្វីនោះទេ រួមទាំងទម្ងន់របស់វាផងដែរ ត្រូវអាស្រ័យទៅលើកាលៈទេសៈពិសេសរបស់ករណីនិមួយៗ" ។

[47] បណ្តឹងឧទ្ធរណ៍ស្តីពីការបកប្រែ, A190/I/1 ។ ដីកាសម្រេចស្តីពីសិទ្ធិនៃការបកប្រែ, A190 ។

[48] បណ្តឹងឧទ្ធរណ៍, C40/5/1, កថាខណ្ឌទី៨-៩, ១១-១៥, ២៧-៣៣, ៨៣-៨៥ ។

[49] *ករណីរបស់ ខៀវ សំផន,* សេចក្តីបង្គាប់របស់ អ.ប.ជ ដល់មេធាវីការពារក្តីទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៥ សីហា ២០០៨, C26/I/27, ERN 00212353-55 (ភាសាអង់គ្លេស) និង ERN 00212359-61 (ភាសាខ្មែរ) កថាខណ្ឌទី៧-១០ ។ សេចក្តីបង្គាប់របស់ អ.ប.ជ ស្តីពីការបន្តកិច្ចដំណើរការនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី០២ តុលា ២០០៨, C26/I/29, ERN 00225296-99 (ភាសាអង់គ្លេស) និង 00225304-07 (ភាសាខ្មែរ) ។

គ្នា[50] ដោយស.ច.ស បានសម្រេចលើសំណើសុំដោះលែង និងការបន្តថិរវេលាឃុំខ្លួន បណ្ដោះអាសន្ន ហើយបានទុកបញ្ហាទាក់ទងនឹងការបកប្រែ និងការចោទប្រកាន់ថា ដំណើរការនីតិវិធីមិនមានយុត្តិធម៌ ជូនទៅ អ.ប.ជ ដើម្បីធ្វើការសម្រេចសេចក្ដី ។

១៣. ទីមួយ គេគួរកត់សំគាល់ថា ស.ច.ស បានបំពេញកាតព្វកិច្ចរបស់ខ្លួនតាមរបៀបមួយ ដោយមិនលំអៀង និងដោយឯករាជ្យ ហើយដីកាសម្រេចរបស់ ស.ច.ស ស្ដីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគី ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ត្រូវបានសម្រេចបន្ទាប់ពីបានពិចារណាលើសិទ្ធិរបស់គ្រប់ភាគីទាំងអស់ ដោយរាប់បញ្ចូលទាំងសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ និងដោយឆាប់រហ័សផង[51] ។ លើសពីនេះ មេធាវីការពារក្ដីបានទទួលស្គាល់ថា ស.ច.ស មិនមានកាតព្វកិច្ចធ្វើការពិចារណាលើសេចក្ដីសម្រេចរបស់ខ្លួនទាក់ទងនឹងការបកប្រែឡើងវិញទេ[52] មុន អ.ប.ជ សម្រេចសេចក្ដីពីបណ្ដឹងឧទ្ធរណ៍ ។ ជាលទ្ធផល មេធាវីការពារក្ដីមិនអាចពឹងផ្អែកលើសេចក្ដីសម្រេចមួយពីមុនរបស់ ស.ច.ស ទាក់ទងនឹងការបកប្រែ ដែលអវិជ្ជមានចំពោះខ្លួនប៉ុន្តែមានលក្ខណៈឯករាជ្យ ដើម្បីធ្វើការសន្និដ្ឋានថា ស.ច.ស មិនគួរនឹងធ្វើសេចក្ដីសម្រេចបដិសេធលើសំណើសុំដោះលែងទាល់តែសោះ ។ ទីពីរ ដោយអនុលោមតាម អ.ប.ជ ការចោទប្រកាន់ថាមានការពន្យារពេល នៅក្នុងនីតិវិធីស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន គឺត្រូវបានធ្វើយុត្តិកម្មជាស្រេចហើយ ដោយសារមេធាវីការពារក្ដីមិនមានឆន្ទៈ ក្នុងការបន្តនីតិវិធីទៅមុខទៀត[53] ។ ទីបី ដោយផ្ទុយពីសេចក្ដីអះអាង

---

[50] ដីកាសម្រេចបន្តការឃុំខ្លួន, C26/4, កថាខណ្ឌទី ១៦៖ "ជាចុងក្រោយ សេចក្ដីសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន ខៀវ សំផន ជាបណ្ដោះអាសន្ន មិនអាស្រ័យទៅលើលទ្ធផលសម្រេចនៃបណ្ដឹងឧទ្ធរណ៍ដែលកំពុងតែមានប្រឆាំងនឹងដីកាស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទិននឹងការបកប្រែទេ " ។

[51] ដីកាសម្រេចស្ដីពីសិទ្ធិនៃការបកប្រែ, A190, កថាខណ្ឌទី A3 ។ ដីកាសម្រេចបន្តការឃុំខ្លួន, C26/4, កថាខណ្ឌទី ១៥ ។

[52] បណ្ដឹងឧទ្ធរណ៍, C40/5/1, កថាខណ្ឌទី ២៩ ។

[53] *ករណីរបស់ ខៀវ សំផន,* សេចក្ដីបង្គាប់របស់ អ.ប.ជ លើពាក្យសុំពន្យារពេលសវនាការ, ចុះថ្ងៃទី២៣ មេសា ២០០៨, C26/I/25, ERN 00180341-44 (ភាសាអង់គ្លេស), ត្រង់ទំព័រ ERN 00180343 ។ កំណត់ហេតុសវនាការរបស់ អ.ប.ជ ចុះថ្ងៃទី២៣ មេសា ២០០៨ ស្ដីពីបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី០២ ឧសភា ២០០៨, C26/I/26, ERN 00185534-41 (ភាសាអង់គ្លេស) ត្រង់លេខ ERN 00185540 ។ សេចក្ដីបង្គាប់របស់ អ.ប.ជ ដល់មេធាវីការពារក្ដី ស្ដីពីបណ្ដឹងឧទ្ធរណ៍ ប្រឆាំងចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី១៥ សីហា ២០០៨, C26/I/27, ERN 00212353-55 (ភាសាអង់គ្លេស) និង 00212359-61 (ភាសាខ្មែរ) ។ សូមមើលបណ្ដឹងឧទ្ធរណ៍ផងដែរ C40/5/1, កថាខណ្ឌទី៣១ ។ សេចក្ដីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះ ស្ដីពីជំហររបស់មេធាវីការពារក្ដីពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន, ចុះ

00275484

C40/5/2



របស់មេធាវីការពារក្តី[54] ស.ច.ស បានថ្លែងយ៉ាងត្រឹមត្រូវនៅក្នុងកថាខណ្ឌទី ១៣ នៃដីកាបដិសេធការដោះលែងថា "ដោយមានការដកបណ្តឹងឧទ្ធរណ៍ សហមេធាវីរបស់ជនត្រូវចោទមានចេតនាបោះបង់សិទ្ធិរបស់ពួកខ្លួន ក្នុងការតទល់នៅចំពោះមុខអាជ្ញាធរតុលាការមានសមត្ថកិច្ច - នៅក្នុងករណីនេះគឺ អង្គបុរេជំនុំជម្រះ - អំពីលក្ខខណ្ឌនានាដែលនីតិវិធីត្រូវបានដំណើរការ" ។

១៤. ទីបួន សហព្រះរាជអាជ្ញា សន្និដ្ឋានថា សេចក្តីសំអាងដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី ៨-៩, ១១-១៥, ២៧-៣៣, ៨៣-៨៥ នៃបណ្តឹងឧទ្ធរណ៍ដែលមានមូលដ្ឋាននៅលើបញ្ហាដោយឡែកដែល អ.ប.ជ នៅមិនទាន់បានពិភាក្សានៅឡើយទេ ។ ទាំង ស.ច.ស និងទាំង អ.ប.ជ មិនដែលបានសន្និដ្ឋានថាសិទ្ធិរបស់ជនត្រូវចោទត្រូវបានបំពាន ដោយសារការមិនមានការបកប្រែឯកសារនៅក្នុងសំណុំរឿងទេ និង/ឬ ការឃុំខ្លួនបណ្តោះអាសន្នគឺខុសច្បាប់ ឬមិនប្រក្រតីនោះដែរ ។ *ជាផលវិបាក ការអះអាងរបស់មេធាវីការពារក្តីមិនបង្កើតបានជាអ្វី ឱ្យបានច្រើនជាងការដែលគ្រាន់តែជាការសន្មតប៉ុណ្ណោះ ៖ "នីតិវិធីខុសច្បាប់ និងជាក់ស្តែងការឃុំខ្លួនបណ្តោះអាសន្នជាការឃុំខ្លួន ដែលធ្វើឡើងស្រេចតែនឹងអំពើចិត្ត"[55] មានកំហុសផ្នែកនីតិវិធីដោយមូលហេតុមានការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ក្រុមការពារក្តី"[56] "នីតិវិធីពុំសមស្រប (...)* ។ ដូច្នេះ ការឃុំខ្លួននេះត្រូវបានធ្វើឡើងដោយបំពាន ហើយ លោក ខៀវ សំផន ត្រូវតែបានទទួលនូវការដោះលែង"[57] ។ មេធាវីការពារក្តីគ្រាន់តែសំអាងទៅលើ

---

ថ្ងៃទី២៧ សីហា ២០០៨, C26/I/28, ERN 00219402-05 (ភាសាអង់គ្លេស), 00218013-16 (ភាសាបារាំង) និង 00218017-20 (ភាសាខ្មែរ) ។ សេចក្តីបង្គាប់របស់ អ.ប.ជ ស្តីពីការបន្តកិច្ចដំណើរការនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី ០២ តុលា ២០០៨, C26/I/29, ERN 00225296-99 (ភាសាអង់គ្លេស) និង 00225304-07 (ភាសាខ្មែរ) ។ សេចក្តីជូនដំណឹង អំពីការដកបណ្តឹងឧទ្ធរណ៍, ចុះថ្ងៃទី០៨ តុលា ២០០៨, C26/I/30, ERN 00231936-42 (ភាសាអង់គ្លេស) និង 00228794-802 (ភាសាខ្មែរ) ។

[54] បណ្តឹងឧទ្ធរណ៍, C40/5/1, កថាខណ្ឌទី២៨៖ (...) "សវនាការស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានពន្យារពេលអស់រយៈពេលជាងប្រាំពីរខែហើយ <u>ហើយជាចុងក្រោយក៏បានលុបចោល</u> ហើយមេធាវីការពារក្តី បានកាត់ពង្រួញឱ្យខ្លីលើកថាខ័ណ្ឌទី៣២ [សង្កត់ធ្ងន់នៅត្រង់ឃ្លាគូសបន្ទាត់ពីក្រោម]៖ ស.ច.ស "ត្រូវមានកាតព្វកិច្ចចាត់វិធានការទាក់ទិននឹងការពន្យារពេលនេះ និងកំហុសនីតិវិធីទាក់ទិនទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន" ។

[55] បណ្តឹងឧទ្ធរណ៍, C40/5/1, កថាខណ្ឌទី ៣០ ។

[56] បណ្តឹងឧទ្ធរណ៍, C40/5/1, កថាខណ្ឌទី ២៨ និង ១៤ ។

[57] បណ្តឹងឧទ្ធរណ៍, C40/5/1, កថាខណ្ឌទី ៨៣ ។

សេចក្ដីសម្រេចមួយដែលជាសម្ពតិកម្មរបស់ អ.ប.ជ ប៉ុណ្ណោះដែលបច្ចុប្បន្ននេះមិនអាចលេចចេញជាការប៉ះពាល់ផ្នែកច្បាប់ ឬមួយក៏មិនអាចជាមូលដ្ឋានអ្វីមួយសម្រាប់ឲ្យ ស.ច.ស សម្រេចចិត្តដោះលែងជនត្រូវចោទទេ ។

១៥. ទីបញ្ចប់ បណ្ដឹងឧទ្ធរណ៍មួយទៅ អ.ប.ជ មិនផ្អាកដំណើរការនីតិវិធីទេ ។ គោលការណ៍នេះត្រូវបានរំលឹកឡើងវិញដោយ ស.ច.ស នៅក្នុងដីកាសម្រេចបន្តការឃុំខ្លួន[58] ។ វិធានផ្ទៃក្នុងមិនបានចែងអំពីផលប៉ះពាល់ថាជា ការផ្អាកដោយសារមានសេចក្ដីសម្រេចរបស់ ស.ច.ស លើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទទេ ។ ការចោទថាមានការបំពានលើសិទ្ធិរបស់មេធាវីការពារក្ដីទាក់ទងនឹងបញ្ហាបកប្រែដែលត្រូវបានថាឡើងវិញនៅគ្រប់សារណាជាលាយលក្ខណ៍អក្សររបស់មេធាវីការពារក្ដី ចាប់តាំងពី ខែមេសា ឆ្នាំ២០០៨ និងមានម្ដងទៀតនៅពេលសវនាការនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៨[59] នៅតែមិនច្បាស់លាស់ និងជាសម្ពតិកម្មសុទ្ធសាធ ។

---

[58] ដីកាសម្រេចបន្តការឃុំខ្លួន, **C26/4**, កថាខណ្ឌទី ១៥-១៦ ។

[59] *ករណីរបស់ ខៀវ សំផន,* សេចក្ដីសម្រេចរបស់ អ.ប.ជ លើសំណើសុំពន្យារពេលសវនាការលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី២៣ មេសា ២០០៨, **C26/I/25**, ERN 00180341-44 (ភាសាអង់គ្លេស) ។ កំណត់ហេតុរបស់ អ.ប.ជ ស្ដីពីសវនាការថ្ងៃទី២៣ មេសា ២០០៨ លើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី០២ ឧសភា ២០០៨, **C26/I/25**, ERN 00185534-44 (ភាសាអង់គ្លេស) ។ សេចក្ដីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះ ស្ដីពីជំហររបស់មេធាវីការពារក្ដីពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី២៧ សីហា ២០០៨, **C26/I/28**, ERN 00219402-05 (ភាសាអង់គ្លេស), 00218013-16 (ភាសាបារាំង) និង 00218017-20 (ភាសាខ្មែរ) ។ សេចក្ដីជូនដំណឹងរបស់មេធាវីការពារក្ដីស្ដីពីការដកបណ្ដឹងឧទ្ធរណ៍, ចុះថ្ងៃទី០៨ តុលា ២០០៨, **C26/I/30**, ERN 00228787-00228793 (ភាសាបារាំង) និង 00231936-42 (ភាសាអង់គ្លេស) ។ សំណើសុំដោះលែងជាបន្ទាន់របស់មេធាវីការពារក្ដី, **C40** ។ សេចក្ដីជំទាស់របស់ក្រុមការពារក្ដីទាក់ទងនឹងការបន្តការឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី១៤ វិច្ឆិកា ២០០៨, **C26/3**, ERN 00238930-41 (ភាសាបារាំង) និង 00238914-23 (ភាសាខ្មែរ) ។ បណ្ដឹងឧទ្ធរណ៍, **C40/5/1** ។ សំណើជាយថាហេតុ និងបន្ទាន់បំផុតដើម្បីស្នើសុំឲ្យមានការដោះលែងឲ្យមានសេរីភាព, ចុះថ្ងៃទី០៤ ធ្នូ ២០០៨, **C26/5/2**, ERN 00249810-14 (ភាសាបារាំង), 00250603-07 (ភាសាអង់គ្លេស) និង 00249810-14 (ភាសាខ្មែរ) ។ សារណាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តចិរវេលាឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី០៤ ធ្នូ ២០០៨, **C26/5/1**, ERN 00251782-98 (ភាសាអង់គ្លេស)។ អត្ថបទប្រតិចារិកនៃសវនាការលើបណ្ដឹងឧទ្ធរណ៍ថ្ងៃទី០៤ ធ្នូ ២០០៨, (អ.ប.ជ ១១) T.S, ERN 00251973-018 (ភាសាអង់គ្លេស) 00252019-67 (ភាសាបារាំង) និង 00252068-114 (ភាសាខ្មែរ) ។ លោក Jacques Vergès បាននិយាយ (នៅត្រង់លេខERN 00251993 ជាភាសាអង់គ្លេស) ថា៖ "ខ្ញុំនៅតែប្រកាន់គោលជំហររបស់ខ្ញុំដដែល ពីព្រោះតុលាការនៅតែស្នើឲ្យខ្ញុំធ្វើដូច្នេះ ប៉ុន្តែខ្ញុំគ្រាន់តែចង់និយាយថា ខ្ញុំនឹងមកហើយមកទៀត គឺសុំឲ្យបកប្រែទាល់តែបាន" ។ *សូមមើលផងដែរ* លិខិតរបស់មេធាវី ខៀវ សំផន ស្ដីពីការអនុវត្តន៍នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលមានឈ្មោះថាសហកម្មឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី៣១ ធ្នូ ២០០៨, **D97/3/5**, ERN 00267726-27 (ភាសាបារាំង), 00270652-53 (ភាសាអង់គ្លេស) និង 00267915-17 (ភាសាខ្មែរ) ។

00275486



សេចក្តីសំអាងដែលបានលើកឡើងដោយមេធាវីការពារក្តី នៅក្នុងសារណាទាំងនោះ បង្កើតបានជាវិធានការនានាសម្រាប់ពន្យារពេល ដែលប្រឆាំងនឹងសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបាននូវការកាត់សេចក្តីមួយដ៏ឆាប់រហ័ស ហើយអាចនឹងក្លាយទៅជា "ការរំលោភបំពានលើនីតិវិធី"ទៀតផង ។ ជាលទ្ធផល ការផ្អាកសេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពីសិទ្ធិ និងកាតព្វកិច្ចក្នុងការបកប្រែ "ភាគីនានាបានដឹងអំពីច្បាប់ដែលកំពុងអនុវត្ត ទាក់ទិននឹងបញ្ហាបកប្រែសំណុំរឿងទៅតាមនីតិវិធីនាដំណាក់កាលនេះ"[60] ។ នៅក្នុងហេតុការណ៍ណាក៏ដោយបើ អ.ប.ជ សម្រេចនៅក្នុងសេចក្តីសម្រេចលើកក្រោយរបស់ខ្លួនទាក់ទងសិទ្ធិ និងកាតព្វកិច្ចរបស់ជនត្រូវចោទថាត្រូវបានរំលោភ ស.ច.ស ចាំបាច់ត្រូវអនុវត្តភ្លាម នូវសេចក្តីសម្រេចដើម្បីធ្វើការដោះលែងគាត់ ។ ការណ៍នេះ បង្កើតបានជាដំណោះស្រាយ មួយដ៏សមស្រប ។ នៅពេលនេះ ដីកាសម្រេចរបស់ ស.ច.ស ចុះថ្ងៃទី១៩ ខែមិថុនា, ថ្ងៃទី២៨ ខែតុលា និងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ រៀងៗគ្នា[61] គឺអាចអនុវត្តបានតាមវិធានផ្ទៃក្នុង រហូតទាល់តែត្រូវបានពិនិត្យឡើងវិញដោយ អ.ប.ជ តាមបណ្តឹងឧទ្ធរណ៍ ។

## *គ. ការយកចិត្តទុកដាក់ក្នុងការអនុវត្តន៍ដំណើរការនីតិវិធី និង លក្ខណៈវិនិច្ឆ័យដទៃទៀតសម្រាប់កំណត់លើការពន្យារពេលសមស្រប*

១៦. មេធាវីការពារក្តី បានអះអាងថាកង្វះខាតក្នុងការយកចិត្តទុកដាក់អនុវត្តនូវដំណើរការនីតិវិធីអស់រយៈពេលមួយឆ្នាំ[62] ។ អ.ប.ជ គួរតែបដិសេធសេចក្តីអះអាងនេះចោល ព្រោះថាសេចក្តីសំអាងរបស់មេធាវីការពារក្តី គឺមិនមានបញ្ជាក់ពីអង្គហេតុពិត និងមិនមានការពាក់ព័ន្ធអ្វីទេ ។

១៧. គេត្រូវយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់ទៅលើលក្ខណៈដ៏ជាក់លាក់នៃការស៊ើបសួរ នៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ។ ដើមបណ្តឹងឧទ្ធរណ៍ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ (ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត) ។ ដើមបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើការស៊ើបសួរ

---

[60] ដីកាសម្រេចបន្តការឃុំខ្លួន, C26/4, កថាខណ្ឌទី ១៥ ។

[61] A190, C40/4 និង C26/4 ។

[62] បណ្តឹងឧទ្ធរណ៍, C40/5/1, កថាខណ្ឌទី៤៤ និង ៨៤-៨៥ ។ សូមមើលកថាខណ្ឌទី៦-១៩ ផងដែរ ។

C40/5/2



អំពីការមានផែនការ ញុះញង់ បញ្ជា ប្រព្រឹត្ត ឬ ជួយជំរុញ ក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬដោយមានការទទួលខុសត្រូវខ្ពស់ លើបទឧក្រិដ្ឋជាច្រើនប្រឆាំងនឹងមនុស្សជាតិ ។ បន្ថែមលើនេះ ដូចដែលបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងនៅក្នុងការដាក់ឯកសារជាបន្តបន្ទាប់[63] ដែលមាននៅក្នុងការចោទប្រកាន់អំពី"ការប្រព្រឹត្តិ" នោះគឺការចូលរួមរបស់ដើមបណ្តឹងឧទ្ធរណ៍នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ("JCE") ក្នុងឋានៈជាសហចារី ដែលបណ្តាលឲ្យមានការប្រព្រឹត្តិនូវបទឧក្រិដ្ឋជាក់ស្តែងជាច្រើន នៅពាសពេញប្រទេសកម្ពុជា និងនៅក្នុងអាណត្តិពេលវេលារបស់អង្គជំនុំជម្រះនេះទាំងស្រុង ។ បទឧក្រិដ្ឋទាំងនេះ គឺឋិតនៅក្នុងចំណោមបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរ និងស្មុគស្មាញជាទីបំផុត ហើយជនត្រូវចោទ បើសិនជាត្រូវបានកាត់ឲ្យជាប់ទោស ត្រូវប្រឈមមុខនឹងសក្តានុពលនៃការជាប់ពន្ធនាគារអស់មួយជីវិត ។

១៨. លើសពីនេះ ដូចដែលបានសំអាងនៅខាងក្រោម (សូមមើលកថាខណ្ឌទី ២៤ ដល់ ៣១) ការពិនិត្យមើលសំណុំរឿងបង្ហាញថាមានការជឿនលឿននៅក្នុងការស៊ើបសួរ ហើយភស្តុតាងដែលបានប្រមូលបញ្ជាក់បន្ថែមអំពីការទទួលខុសត្រូវរបស់ដើមបណ្តឹងឧទ្ធរណ៍ ចំពោះបទឧក្រិដ្ឋដែលគាត់ត្រូវបានចោទប្រកាន់ ។

១៩. នៅក្នុងដីកាបដិសេធការដោះលែង សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថា ការកន្លងផុតទៅនៃពេលវេលា គឺទាក់ទងទៅនឹងការកំណត់ថាតើ មូលដ្ឋានសម្រាប់បន្តការឃុំខ្លួនបណ្តោះអាសន្ន នៅតែមានអត្ថិភាពដដែល ឬយ៉ាងណា[64] ។ នៅពេលដែលរយៈពេលត្រូវបានពិចារណាដោយតុលាការ អន្តរជាតិនានា ថាជាកត្តាពាក់ព័ន្ធនៅក្នុងការកំណត់អំពីនីត្យានុកូលភាព

---

[63] *ករណីរបស់ អៀង សារី,* ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិស្នើសុំរបស់ អៀង សារី ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី១១ សីហា ២០០៨, ERN 00211956-70, **D97/II** ។ សេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី៣១ ធ្នូ ២០០៨, **D97/8**, ERN 00268566-92 (*ភាសាអង់គ្លេស*) ។ ដីកាសម្រេចលើពាក្យសុំស្តីពីទម្រង់នៃការទទួលខុសត្រូវ ដែលមានឈ្មោះថា សហកម្មឧក្រិដ្ឋកម្មរួមរបស់ ស.ច.ស, ចុះថ្ងៃទី១៦ កញ្ញា ២០០៨, **D97/III**, ERN 00224208-09 (*ភាសាអង់គ្លេស*) ។

[64] ដីកាបដិសេធការដោះលែង, **C40/4**, កថាខណ្ឌទី២៧ ។

នៃការឃុំខ្លួន[65] មេធាវីការពារក្ដីមិនបានបង្ហាញថាតើ ការឃុំខ្លួនរយៈពេលមួយឆ្នាំ មានបុរេវិនិច្ឆ័យទៅលើករណីរបស់ ដើមបណ្ដឹងឧទ្ធរណ៍ទៅតាមរបៀបមួយដែលបានរារាំងដល់ការកាត់សេចក្ដីមួយដ៏ត្រឹមត្រូវ ឬ របៀបដែលវាអាចធ្វើយុត្តិកម្មដល់ការដោះលែងជាបណ្ដោះអាសន្ន បានតាមរបៀបណានោះ ឡើយ ។ វាត្រូវតែបានគេពោលថាតុលាការ ICTR នៅមិនទាន់បានរកឃើញនូវរយៈពេល ដែលការឃុំខ្លួនមុនពេលជំនុំជម្រះមិនសមស្របនៅឡើយ[66] ហើយថានៅក្នុងការវាយតម្លៃលើ ការឃុំខ្លួនមុនពេលជំនុំជម្រះដែលសមស្រប តុលាការ ICTY បានពិចារណាយ៉ាងជាប់លាប់ អំពីរយៈពេលឃុំខ្លួនមួយដែលយូរជាងថាជាការសមស្រប ដោយសារតែសភាពធ្ងន់ធ្ងរនៃ ឧក្រិដ្ឋកម្មនានាដែលពាក់ព័ន្ធ[67] ។ លើសពីនេះ វិធានផ្ទៃ

---

[65] *រដ្ឋអាជ្ញា ទល់នឹង Tihomir Blaskic,* សេចក្ដីសម្រេចបដិសេធលើញត្តិស្នើសុំដោះលែងបណ្ដោះអាសន្ន, សំណុំរឿងលេខ IT-94-14-, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២០ ធ្នូ ១៩៩៦ (C20/3, ប្រភពច្បាប់ ៣)៖ តុលាការ ICTY បានដាក់នៅក្នុងសម្រេចថា ដើម្បីកំណត់អំពីរយៈពេលធម្មតា ដែលសមស្របក្នុងការឃុំខ្លួនបណ្ដោះអាសន្ន ជាចាំបាច់គេត្រូវវាយតម្លៃអំពីកាលៈទេសៈនីមួយៗទៅតាមលក្ខណៈវិនិច្ឆ័យដូចតទៅ៖ ក) រយៈពេលនៃការឃុំខ្លួនដែលមានប្រសិទ្ធិភាព, ខ) រយៈពេលនៃការឃុំខ្លួនដែលពាក់ព័ន្ធទៅនឹងប្រភេទនៃបទឧក្រិដ្ឋ, គ) ផលវិបាកនៃការ ឃុំខ្លួនទៅលើជនជាប់ឃុំតាមផ្លូវកាយ និងផ្លូវចិត្ត, ឃ) ភាពស្មុគ្រស្មាញនៃសំណុំរឿង និងការស៊ើបអង្កេត, ង) ការប្រព្រឹត្តិទៅនៃ ដំណើរការនីតិវិធីទាំងមូល ។ ស្ថានភាពនៅសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ក្នុងសំណុំរឿងរបស់ *រដ្ឋអាជ្ញា ទល់នឹង Germain Katanga និង Mathieu Ngudjolo Chui,* ការពិនិត្យឡើងវិញលើសេចក្ដីសម្រេចស្ដីពីសំណើសុំឲ្យដោះលែងឈ្មោះ Mathieu Ngudjolo Chui ជាបណ្ដោះអាសន្ន, សំណុំរឿងលេខ 01/04-01/07, អង្គបុរេជំនុំជម្រះរបស់តុលាការ ICC, ចុះថ្ងៃទី២៣ កក្កដា ២០០៨, ទំព័រទី ១២ (C22/5/7, ប្រភពច្បាប់ 4) ។

[66] តុលាការ ICTR បានរកឃើញនូវភាពស្មុគ្រស្មាញនៃរឿងក្ដីដែលទាក់ទិនទៅនឹងការសម្រេចថារយៈពេលនៃការឃុំខ្លួនមុនពេលជំនុំជម្រះសមស្រប គឺមានចំនួនបួនឆ្នាំកន្លះ ឬប្រាំឆ្នាំ ។ សូមមើលជាបន្តបន្ទាប់នូវករណី *រដ្ឋអាជ្ញា ទល់នឹង Casimir Bizimungu, Justin Mugenzi, Jérome-Clément Bicamumpaka and Prosper Mugiraneze,* សេចក្ដីសម្រេចលើពាក្យសុំរបស់ *Prosper Mugiraneze* សុំឲ្យបើកសវនាការ ឬរកដំណោះស្រាយផ្សេងៗទៀតលើសំណើរបស់គាត់ ដែលសុំឲ្យបដិសេធលើការរំលោភសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវការជំនុំជម្រះមួយដោយគ្មានការពន្យារពេលសមស្រប, សំណុំរឿងលេខ ICTR-99-50, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី០៣ វិច្ឆិកា ២០០៤, កថាខណ្ឌទី ២៦ (C20/3/I, ប្រភពច្បាប់ ៤) ។ *រដ្ឋអាជ្ញា ទល់នឹង Kanyabashi,* សេចក្ដីសម្រេចលើពាក្យសុំរបស់មេធាវីសុំឲ្យដោះលែងជនត្រូវចោទជាបណ្ដោះអាសន្ន, សំណុំរឿងលេខ ICTR-96-15-T, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២១ កុម្ភៈ ២០០១ (C20/5/7.3) ។

[67] ឧទាហរណ៍ដូចជា *ក្នុងករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង Blaskic,* ដីកាសម្រេចបដិសេធលើញត្តិស្នើសុំដោះលែងបណ្ដោះអាសន្ន, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី២០ ធ្នូ ១៩៩៦ (C20/3, ប្រភពច្បាប់ 3) ។ *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង Mrda,* ដីកាសម្រេចលើសំណើរបស់ Darko Mrda ដែលស្នើសុំដោះលែងបណ្ដោះអាសន្ន, សំណុំរឿងលេខ IT-02-59-PT, អង្គជំនុំជម្រះសាលាដំបូងទីII នៃតុលាការ ICTY , ចុះថ្ងៃទី១៥ មេសា ២០០២ (C11/11, ប្រភពច្បាប់ C19) ។

ក្នុងមានការការពារទល់នឹងការឃុំខ្លួន បណ្ដោះអាសន្នដែលមិនមានកំណត់[68] ។ ដោយសារតែ កាលៈទេសៈនៃករណីនេះ និង យុត្តិសាស្ត្រអន្តរជាតិ រយៈពេលនៃការឃុំខ្លួនដើមបណ្ដឹង ឧទ្ធរណ៍ជាបណ្ដោះអាសន្ន គឺមានលក្ខណៈសមស្របតាមវិធាន៩.៣ នៃកតិកាសញ្ញាអន្តរជាតិ ស្ដីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិ នយោបាយ (ICCPR) ។

### *ឃ. ការអនុវត្តន៍ឆន្ទានុសិទ្ធិក្នុងការពិចារណាលើការឃុំខ្លួន*

២០. ចៅក្រម ឬអង្គជំនុំជម្រះ មានឆន្ទានុសិទ្ធិក្នុងការសន្និដ្ឋានថា ការឃុំខ្លួនមុនពេលជំនុំជម្រះ គឺជាវិធានការចាំបាច់ ហើយនិងធ្វើការបដិសេធលើសំណើសុំដោះលែង[69] ។ ឆន្ទានុសិទ្ធិ បែប នេះជាទូទៅ គឺត្រូវបានអនុវត្តដោយការពិចារណាទៅគ្រប់លើឯកសារ និង គ្រប់អង្គហេតុពាក់ ព័ន្ធទាំងអស់នៅក្នុងសំណុំរឿង ដោយរាប់ទាំងស្ថានទម្ងន់នៃបទចោទ ភាពសមហេតុផលនៃ ភស្តុតាង អាកប្បកិរិយានិងការប្រព្រឹត្តិពីមុននិងបច្ចុប្បន្នរបស់ចុងចោទ ផលប្រយោជន៍របស់ សាក្សីនិងជនរងគ្រោះ ព្រមទាំងផលប្រយោជន៍នៃយុត្តិធម៌ទាំងមូល[70] ។ ការណ៍នេះ គឺត្រូវគ្នា ទៅនឹង ការអនុវត្តន៍ដែលគេបានទទួលយកនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបាន អនុម័តដោយអង្គជំនុំជម្រះនេះ[71] ។

### *ង. លក្ខខណ្ឌចាំបាច់ក្នុងការឃុំខ្លួន*

---

[68] ថ្វីបើមានស្ថានទម្ងន់ទោសនៃបទចោទប្រកាន់ដែលត្រូវបានជំនុំជម្រះដោយ អ.វ.ត.ក ក៏វិធាន៦៣.៦ និង៧ ចែងអំពីការថែរក្សាការពារ ដែលរួមមានអំពីអង្គហេតុដែលថា គ្មានជនជាប់ចោទណាម្នាក់នៅចំពោះមុខ អ.វ.ត.ក អាចត្រូវបានដាក់ឃុំខ្លួនបណ្ដោះអាសន្ន ក្នុងរយៈសរុបលើសពីបី(៣)ឆ្នាំ បានទេ ។

[69] មេធាវីការពារក្ដីបានទទួលស្គាល់ថា "ហេតុដូចនេះ សហចៅក្រមស៊ើបអង្កេត មានសិទ្ធិអំណាចទូលំទូលាយក្នុងការចេញសេចក្ដីអនុញ្ញាតលើការដោះលែងរបស់ ខៀវ សំផន ។ សហចៅក្រមស៊ើបអង្កេតត្រូវតែធ្វើការបកស្រាយលើអង្គហេតុនានាដោយការពិចារណាផ្អែកទៅលើកាលៈទេសៈជារួមទាំងមូលនៃករណីរឿង", ពាក្យសុំដោះលែងជាបន្ទាន់, C40, កថាខណ្ឌទី២២ ។

[70] *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង Ljube Boskoski និង Johan Tarculovski*, ដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្ខំរបស់ Johan Tarculovski ស្ដីពីការដោះលែងបណ្ដោះអាសន្ន, សំណុំរឿងលេខ IT-04-82-AR65.4, របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី២៧កក្កដា២០០៧, កថាខណ្ឌទី៤, ERN 00153946-54 (ភាសាអង់គ្លេស), (C40/5/1, ប្រភពច្បាប់ 5) ។

[71] ករណីរឿងរបស់កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី៣ ធ្នូ ២០០៧, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧- អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០១), C5/45, ERN 154284-302 (ភាសាអង់គ្លេស), កថាខណ្ឌទី២៧ [ដែលតទៅទៀតនៅក្នុងនេះហៅថា ដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ ឌុច ស្ដីពីការឃុំខ្លួន] ។

២១. តាមវិធាន ៦៣.៣ សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ បានតែក្នុងលក្ខខណ្ឌដូចខាងក្រោម៖

(ក) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម, និង

(ខ) សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បី៖

(១) រារាំងកុំឲ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ។

(២) ថែរក្សាភស្តុតាង ឬការពារមិនឲ្យបំផ្លាញភស្តុតាង ។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី ។

(៤) ការពារសន្តិសុខឲ្យជនដែលត្រូវចោទ, ឬ

(៥) រក្សាសណ្ដាប់ធ្នាប់សាធារណៈ ។

២២. ទឡ្ហីករណ៍សម្រាប់ឃុំខ្លួនចំនួនប្រាំតាមវិធាន ៦៣.៣.ខ គឺដាច់ដោយឡែកពីគ្នា[72] ។ មិនមានលក្ខខណ្ឌតម្រូវណាមួយដែលត្រូវតែឲ្យ ស.ច.ស រកឲ្យឃើញថាមានគ្រប់ទឡ្ហីករណ៍នីមួយៗមុននឹង ស.ច.ស ពិចារណាថាការឃុំខ្លួនគឺជាវិធានការចាំបាច់មួយ ឬថាការបន្តថិរវេលារបស់វាត្រូវបានអនុញ្ញាត ។ ផ្ទុយទៅវិញ បើ ស.ច.ស ពិចារណាថាមានទឡ្ហីករណ៍ណាមួយ ក្នុងចំណោមទឡ្ហីករណ៍ទាំងប្រាំនេះ នោះគឺត្រូវទៅតាមលក្ខខណ្ឌសម្រាប់ការឃុំខ្លួន នោះហើយ ។ វិធានការនេះ ក៏ត្រូវបានតុលាការព្រហ្មទណ្ឌផ្សេងៗទៀត ដែលធ្វើការពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិដ៏ធ្ងន់ធ្ងរស្រដៀងគ្នានេះ យកលំនាំតាមផងដែរ[73] ។

---

[72] ដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ អៀង សារី, C22/1/74, កថាខណ្ឌទី១២១ ។

[73] *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង Sainovic និង Odjanic,* ដីកាសម្រេចបដិសេធលើសំណើសុំអនុញ្ញាតប្ដឹងឧទ្ធរណ៍របស់ Odjani, សំណុំរឿងលេខ IT-99-37-AR65.2, របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី២៧ មិថុនា ២០០៣, ERN 00149692-95, ត្រង់ទំព័រ ERN 00149494 (D29, ប្រភពច្បាប់ 16) ហើយដែលត្រូវបានអនុម័តយកតាមដោយ អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក ។ ដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ ឌុច, C5/45, កថាខណ្ឌទី៥៩ ។

00275491

C40/5/2



## ៥. អំពីអង្គហេតុ និង សេចក្ដីសំអាង

### *ក. បណ្ដឹងឧទ្ធរណ៍មិនបានកំណត់អំពីស្ថានការណ៍ប្រែប្រួល ដើម្បីធ្វើយុត្តិកម្មលើការដោះលែងជនត្រូវចោទជាបណ្ដោះអាសន្នទេ*

២៣. ដើមបណ្ដឹងឧទ្ធរណ៍មិនបានកំណត់អំពីភស្តុតាង ឬស្ថានការណ៍ប្រែប្រួលដ៏សំខាន់ណាមួយ ដើម្បីធ្វើយុត្តិកម្មលើការដោះលែងដើមបណ្ដឹងឧទ្ធរណ៍ជាបណ្ដោះអាសន្នទេ ឬ សូម្បីតែការប្រែប្រួលលក្ខខណ្ឌនៃការឃុំខ្លួនណាមួយ ក៏មិនបានកំណត់ដែរ ។ មេធាវីការពារក្ដីបែរជាពឹងផ្អែកលើសេចក្ដីសំអាងទាក់ទងទៅនឹងភាសា ដោយលើកឡើងថា សេចក្ដីសម្រេច បដិសេធសំណើសុំដោះលែងជនត្រូវចោទត្រូវបានសម្រេចតាមតែអំពើចិត្ត ហើយថា សេចក្ដីសម្រេចបែបដូច្នោះ គឺមិនចាំបាច់ឡើយ ។ បណ្ដឹងឧទ្ធរណ៍មិនបានជូនអង្គហេតុសម្រាប់គាំទ្រ ដល់ការអះអាងទាំងនេះទេ ។ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ស.ច.ស បដិសេធមិនព្រម ដោះលែងជនត្រូវចោទជាបណ្ដោះអាសន្នទេ ពីព្រោះការឃុំខ្លួននៅតែងត្រូវទៅតាមលក្ខខណ្ឌ នានានៃវិធាន៦៣.៣ ហើយថិរវេលាឃុំខ្លួនជនត្រូវចោទគឺមិនហួសហេតុនោះទេ[74] ។ មេធាវីការពារក្ដីមិនបានដាក់ជូននូវភស្តុតាងណាមួយឡើយ ចាប់តាំងពីមានដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នដំបូង នៅខែវិច្ឆិកា ឆ្នាំ២០០៧ ដែលស្តុតាងនោះសម្រាប់បង្ហាញពីស្ថានការណ៍ប្រែប្រួល ដើម្បីធ្វើយុត្តិកម្មដល់ការពិចារណាឡើងវិញលើសេចក្ដីសម្រេចរបស់ ស.ច.ស ។

### ខ. មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ដើមបណ្ដឹងឧទ្ធរណ៍ធ្លាប់បានប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់មួយ ឬច្រើន - វិធាន ៦៣.៣.ក

២៤. សំណុំរឿងបច្ចុប្បន្ននេះមានភស្តុតាង ដែលនៅក្នុងដំណាក់កាលនេះ អ្នកសង្កេតការណ៍ឯករាជ្យអាចនឹងយល់ឃើញបានថា ដើមបណ្ដឹងឧទ្ធរណ៍អាចនឹងប្រព្រឹត្តបទឧក្រិដ្ឋនានា ដែលខ្លួនគាត់កំពុងត្រូវបានគេធ្វើការស៊ើបសួរនាពេលបច្ចុប្បន្ននេះ ។ នេះគឺជាការពិបាកមួយដែលអ.ប.ជ[75] បានសម្រេច និងដែលត្រូវបានអនុវត្តដោយ ស.ច.ស[76] ។

---

[74] ដីកាសម្រេចបដិសេធលើសំណើសុំអនុញ្ញាតប្ដឹងឧទ្ធរណ៍, C40/4, កថាខណ្ឌទី៥-២២ និង ២៦-៣០ ។

[75] សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា ស្ដីពីការឃុំខ្លួន, C11/54, កថាខណ្ឌទី៤៦ ។ សាលដីកាសម្រេចរបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី៩ កក្កដា ២០០៨, C22/1/27, ERN 00201633-49

២៥. ទោះបីជាមេធាវីការពារក្តីបានធ្វើដូច្នេះ នៅក្នុងបណ្តឹងឧទ្ធរណ៍ពីមុន[77] ក៏ដោយ ក៏បច្ចុប្បន្ននេះ ពួកគាត់មិនបានដាក់ជូននូវសេចក្តីសំអាងដែលមានមូលដ្ឋាននៅលើវិធាន៦៣.៣.ក ទេ ។ តាមពិត មេធាវីការពារក្តីមិនបានធ្វើការជំទាស់ឱ្យបានហ្មត់ចត់ អំពីអត្ថិភាពនៃមូលហេតុដែល ត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទនោះធ្លាប់បានប្រព្រឹត្តបទល្មើសនានា ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាចាត់ទុកថាជាការចាំបាច់មួយដែលគ្រាន់តែលើកឡើងនូវធាតុផ្សំថ្មីខ្លះៗ តាមវិធាន ៦៣.៣.ក ដែលធ្លាប់បានធ្វើអន្តរាគមចាប់តាំងពីមានការចាប់ខ្លួនដើមបណ្តឹងឧទ្ធរណ៍មក ។ ចំណែកឯភស្តុតាងគាំទ្រដល់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលខ្លួនវាផ្ទាល់គឺនៅតែមានលក្ខណៈគ្រប់គ្រាន់ដដែល ដើម្បីធ្វើយុត្តិកម្មទៅលើលក្ខណៈវិនិច្ឆ័យអំពី "មានមូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់យ៉ាងច្បាស់" សហព្រះរាជអាជ្ញា បានដាក់បញ្ចូលដោយយោងទៅតាមឯកសារដែលបានដាក់ជូន នៅត្រង់កថាខណ្ឌទី ២៤-២៦ និង ៣៣-៥២ នៃ "ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០០៧"[78] ។ សហព្រះរាជអាជ្ញា ក៏បានយោងផងដែរទៅលើភស្តុតាងថ្មីដែលបានរៀបរាប់យ៉ាងពិស្តារនៅក្នុងដីកាបដិសេធការដោះលែងរបស់ ស.ច.ស ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌទី ៧-១១[79] ។

២៦. នៅក្នុងដីកាសម្រេចលើការដេញដោលរបស់ខ្លួន ស.ច.ស បានកត់សម្គាល់ថា មូលហេតុនានាដែលត្រូវបានរកឃើញ កំពុងបន្តនៅមានអត្ថិភាពនៅឡើយ ដែលនាំឱ្យជឿជាក់យ៉ាងច្បាស់ថា ដើមបណ្តឹងឧទ្ធរណ៍ធ្លាប់បានប្រព្រឹត្តបទល្មើសនានា ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿង

---

(ភាសាអង់គ្លេស), កថាខណ្ឌទី២១ [*ចាប់ពីពេលនេះតទៅហៅថា* សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ស្តីពីការឃុំខ្លួន] ។ សាលដីកា សម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ អៀង សារី, C2/1/73, កថាខណ្ឌទី៧១ ។

[76] ដីកាសម្រេចបដិសេធលើសំណើសុំដោះលែង, C40/4, កថាខណ្ឌទី៧ ។

[77] សារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ វិច្ឆិកា២០០៧ និងថ្ងៃទី២១ ធ្នូ ២០០៧, C26/1/3, ERN 00158303-14 (ភាសាអង់គ្លេស) ។

[78] *ករណីរឿងក្តីរបស់ ខៀវ សំផន,* ចម្លើយតបរបស់ សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចដោះលែងបណ្តោះអាសន្ន, ចុះថ្ងៃទី១៩ វិច្ឆិកា ២០០៧ និងថ្ងៃទី៦ កុម្ភៈ ២០០៨, C26/1/9, ERN 00160767-95 (ភាសាអង់គ្លេស) ។

[79] ដីកាសម្រេចបដិសេធការដោះលែង, C40/4 ។

ឲ្យស៊ើបសួរ ។ ស.ច.ស ក៏បានកត់សម្គាល់ផងដែរថាការស៊ើបសួរមានការជឿនលឿនទៅមុខ ចាប់តាំងពីមានការចាប់ខ្លួនជនត្រូវចោទមក ដោយសារប្រមូលបាននូវឯកសារមួយចំនួនជាភស្តុតាងបន្ថែម ហើយថាការកន្លងផុតទៅនៃពេលវេលាត្រូវបានពិចារណាហើយ[80] ។

២៧. សហព្រះរាជអាជ្ញា ស្នើឲ្យ អ.ប.ជ ធ្វើការបញ្ជាក់អំពីការរកឃើញពីមុននូវអត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយដូចដែលបានចោទប្រកាន់[81] ។ ជាការបង្ហាញឲ្យឃើញយ៉ាងច្បាស់ក្នុងការពិនិត្យសំណុំរឿងឡើងវិញ ដែលថាឥឡូវនេះ មូលដ្ឋាននៃការជឿជាក់នេះគឺកាន់តែរឹងមាំឡើងជាងកាលពីមួយឆ្នាំមុនទៅទៀត ដោយសារតែភស្តុតាងដាក់បន្ទុកទៅលើដើមបណ្តឹងឧទ្ធរណ៍បានកើនឡើងទាំងចំនួន និងទាំងស្ថានទម្ងន់ក្នុងប៉ុន្មានខែថ្មីៗនេះ ។ ស.ច.ស បានចេញដីកាចាត់ឲ្យស៊ើបសួរជំនួសចំនួន យ៉ាងហោចណាស់ដប់បី (១៣) ដែរ នៅក្នុងសំណុំរឿងលេខ ០០២ (ឯកសារលេខ D25, D40, D43, D78, D82, D91, D92, D93, D94, D104, D107, D115 និង D123)[82] ហើយ ស.ច.ស ឬអ្នកស៊ើបអង្កេតរបស់ខ្លួន បានស្តាប់ចម្លើយសាក្សីជាងមួយរយ (១០០) នាក់ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មទាំងឡាយ ដែលជនទាំងប្រាំរូប ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងនោះ ដោយរាប់បញ្ចូលទាំងដើមបណ្តឹងឧទ្ធរណ៍ផង ថាអាច

---

[80] ដីកាសម្រេចបន្តថិរវេលា, C26/4, កថាខណ្ឌទី២៥-២៥ ដែលយោងទៅលើកថាខណ្ឌទី៧-១១ នៃដីកាសម្រេចបដិសេធការដោះលែងរបស់សហចៅក្រមស៊ើបអង្កេត, C40/4 ។

[81] នៅក្នុងសាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, អង្គបុរេជំនុំជម្រះបានធ្វើការកត់សំគាល់ថា ពាក្យ "បានប្រព្រឹត្ត" គួរតែត្រូវបានបកស្រាយថា "នាំមកនូវការត្រូវទទួលខុសត្រូវជាបុគ្គល" ដែលក្នុងនោះរួមមានការរៀបចំផែនការ, ការញុះញង់, ការបញ្ជា, ការជួយនិងទំនុកបំរុង, ឬការប្រព្រឹត្ត និងការទទួលខុសត្រូវរបស់ថ្នាក់លើ: ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អៀង សារី ស្តីពីការឃុំខ្លួន, C22I/74, កថាខណ្ឌទី៧១ ។

[82] ក្នុងចំណោមដីកាចាត់ឲ្យស៊ើបសួរជំនួសទាំងនោះ មានដីកា៣ ដែលទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី: D25 (កំណត់ហេតុស្តាប់ចម្លើយសាក្សី៣០រូប), D40 (កំណត់ហេតុស្តាប់ចម្លើយសាក្សី២៥រូប), D91 (កំណត់ហេតុស្តាប់ចម្លើយសាក្សី២៩រូប), D92 (កំណត់ហេតុស្តាប់ចម្លើយសាក្សី៨រូប), D94 (កំណត់ហេតុស្តាប់ចម្លើយសាក្សី១០រូប), D107 (កំណត់ហេតុស្តាប់ចម្លើយសាក្សីយ៉ាងតិចក៏១រូបដែរ ), D115 [បានលុបចោល] និង D123 (កំណត់ហេតុស្តាប់ចម្លើយសាក្សី៣រូប) ដែលជាសរុបទាំងអស់មានកំណត់ហេតុស្តាប់ចម្លើយសាក្សីយ៉ាងតិចក៏ ១១៨ដែរ ដែលត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង។ ក៏ប៉ុន្តែតាមសហចៅក្រមស៊ើបអង្កេតថា មានដីកាចាត់ឲ្យស៊ើបសួរជំនួសជាច្រើនដែលកំពុងតែអនុវត្ត។ មិនគួរមានការភ្ញាក់ផ្អើលទេ ដែលតាមធម្មតា ភាគីនានាត្រូវបានគេជូនដំណឹងអំពីអត្ថិភាពនៃដីកាចាត់ឲ្យស៊ើបសួរជំនួសនៅក្រោយពេលដែលបានអនុវត្តរួចហើយបែបនេះ។ ទំនងជាមានកំណត់ហេតុស្តាប់ចម្លើយសាក្សីជាច្រើនទៀតដែលត្រូវបានប្រមូលចងក្រងដោយ ការិយាល័យសហចៅក្រមស៊ើបអង្កេត ចាប់តាំងពីពេលកំណត់ហេតុស្តាប់ចម្លើយសាក្សីត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងរួចមក ។

បានប្រព្រឹត្ត ។ បន្ថែមលើនេះ បរិបទសំខាន់ដែលមាននៅក្នុងសំណុំរឿងលេខ ០០១ ដែលភាគច្រើនពាក់ព័ន្ធទៅនឹងករណីរបស់ដើមបណ្តឹងឧទ្ធរណ៍ ត្រូវបានដាក់បញ្ចូលទៅក្នុង សំណុំរឿងលេខ ០០២ រួចហើយ តាមរយៈការជូនដំណឹងមួយរបស់ ស.ច.ស ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨[83] ។ កំណត់ហេតុសួរចម្លើយឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច មានចំនួនម្ភៃប្រាំបី (២៨) កំណត់ហេតុ ដែលបានធ្វើឡើងក្នុងបរិបទនៃសំណុំរឿងលេខ ០០១ ត្រូវបាន ស.ច.ស ដាក់បញ្ចូលទៅក្នុងសំណុំរឿងលេខ ០០២ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨ រួចជាស្រេចហើយ[84] ។ លើសពីនេះ [បានលុបចោល][85] [86] ។

២៨. សហព្រះរាជអាជ្ញា ក៏បានចូលរួមចំណែកដល់ការស៊ើបសួរផងដែរ ដោយការដាក់ឯកសារភស្តុតាងមួយចំនួនធំចាប់តាំងពីពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងពីពេលចាប់ខ្លួនដើមបណ្តឹងឧទ្ធរណ៍មក[87] ។ គួរកត់សំគាល់ថា ភស្តុតាងទាំងឡាយដែលសហចៅក្រមស៊ើបអង្កេត បានដាក់បញ្ចូលនៅក្នុងសំណុំរឿងតាមសំណើរបស់ សហព្រះរាជអាជ្ញា (គឺដីកាបញ្ជូនរឿងឱ្យស៊ើបសួរ និងការដាក់ឯកសារជូនជាបន្តបន្ទាប់មកទៀត) ក៏ដូចជាភស្តុតាងដែលប្រមូលបានកាលពីឆ្នាំមុន ដោយសហចៅក្រមស៊ើបអង្កេត គឺគ្របដណ្តប់ទៅលើគ្រប់ទម្រង់ និងប្រភេទទាំងអស់នៃការចូលរួមចំណែករបស់ដើមបណ្តឹងឧទ្ធរណ៍ នៅក្នុងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលរូបគាត់ត្រូវបានចោទប្រកាន់ ដែលក្នុងនោះរួមមាន ភស្តុតាងពីទីកន្លែងកើតហេតុ, ភស្តុតាងដែលផ្សារភ្ជាប់ទីកន្លែងកើតហេតុទៅនឹងរចនាសម្ព័ន្ធមេដឹកនាំ ដែលនៅក្នុងនោះដើមបណ្តឹងឧទ្ធរណ៍បានអនុវត្តនូវសិទ្ធិអំណាចក្នុងការបញ្ជា, ភស្តុតាងដែលគាំទ្រអំពីការចូលរួមរបស់គាត់នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ព្រមទាំងភស្តុតាងដែលគាំទ្រ

---

[83] *ករណីរបស់ នួន ជា et al,* កាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨, D108, ERN 00236076-77 (ភាសាអង់គ្លេស) និងឧបសម្ព័ន្ធរបស់វា D108/1 ។

[84] *ករណីរបស់ នួន ជា et al,* កាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨, D86, ERN 00194661 -67 (ភាសាអង់គ្លេស) ។

[85] [បានលុបចោល]

[86] [បានលុបចោល]

[87] [បានលុបចោល]

ធាតុផ្សំខាងយុត្តាធិការ ដូចជា ការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធ ប្រឆាំងនឹងប្រជាជនស៊ីវិល ។

២៩. ដូចដែលបានលើកឡើងយ៉ាងលំអិតដោយ សហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាសម្រេចបដិសេធការដោះលែង ត្រង់កថាខណ្ឌទី៩ មានចម្លើយសាក្សីយ៉ាងតិចណាស់ក៏១២នាក់ដែរ ដែលបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេត របស់ការិយាសហចៅក្រមស៊ើបអង្កេត នៅចន្លោះខែតុលា ឆ្នាំ២០០៧ និង ខែមីនា ឆ្នាំ២០០៨ ដែលត្រូវបានគាំទ្រដោយភស្តុតាងដទៃទៀត ដែលបញ្ជាក់ការពិតដែលស៊ីគ្នាអំពីការដឹង និងការចូលរួមចំណែករបស់ជនត្រូវចោទ នៅក្នុងឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានធ្វើការចោទប្រកាន់ទៅលើរូបគាត់ ក្នុងឋានៈរបស់គាត់ ជាប្រធានរដ្ឋ (ប្រធានគណៈប្រធានរដ្ឋ) ជាមេដឹកនាំនៅក្នុងការិយាល័យនយោបាយរបស់មជ្ឈិមបក្ស (មន្ទីរ៨៧០) និងជាសមាជិកពេញសិទ្ធិនៃ គណៈកម្មាធិការមជ្ឈិមបក្សនៃ បក្សកុម្មុយនីស្តកម្ពុជា[88] ។

៣០. [បានលុបចោល][89] [90] [91] ។

៣១. ជាចុងក្រោយ ចាំបាច់ត្រូវតែលើកឡើងបញ្ជាក់ថា នៅក្នុងពេលដែលជនត្រូវចោទដទៃៗទៀតបានដាក់សំណើសុំឱ្យមានការស៊ើបសួរនោះ ដើមបណ្តឹងឧទ្ធរណ៍រូបនេះមិនបានដាក់សំណើអ្វីនេះទេ ។ សហចៅក្រមស៊ើបអង្កេតមិនឃើញមានភស្តុតាងដោះបន្ទុកណា ដែលមានសារៈសំខាន់ដែលអាចលប់លើការសម្រេចអំពី "អត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញនឹងជឿជាក់យ៉ាងច្បាស់" នោះទេ ។ មកទល់ថ្ងៃនេះដើមបណ្តឹងឧទ្ធរណ៍មិនបានដាក់ឯកសារណាមួយ ឯកសារដែលធ្វើឱ្យភស្តុតាងដែលដោះបន្ទុកតិចជាងនេះឆ្ងាយ ចូលទៅក្នុងសំណុំរឿង ដែលជម្រុញឱ្យត្រូវតែធ្វើការពិនិត្យពិចារណាឡើងវិញទៅលើការសម្រេចនេះទេ ។

---

[88] ដីកាបដិសេធការដោះលែង, C40/4 [បានលុបចោល]

[89] [បានលុបចោល]

[90] [បានលុបចោល]

[91] [បានលុបចោល]

## *គ. ការឃុំខ្លួនបណ្តោះអាសន្នស្ថិតនៅជាវិធានការណ៍មួយដ៏ចាំបាច់ដដែល*

៣២. មេធាវីការពារក្តីបានធ្វើការតវ៉ាជំទាស់ ទៅនឹងនៃលក្ខខណ្ឌជាជំនួសចំនួនបួន(៤) ដែលនៅតែមានជាបន្តដែលបានចែងនៅក្នុងវិធាន ៦៣.៣.ខ.(១), (២), (៤), និង(៥) នៃវិធានផ្ទៃក្នុងនោះទេ។ មេធាវីការពារក្តីក៏បានធ្វើការចោទប្រកាន់ផងដែរថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធលើសំណើសុំដោះលែងរបស់ជនត្រូវចោទ គឺត្រូវបានធ្វើឡើងដោយផ្អែកតែទៅលើមូលដ្ឋាននៃស្ថានទម្ងន់ទោសនៃ បទចោទប្រឆាំងនឹង ខៀវ សំផន តែប៉ុណ្ណោះ[92] ។

៣៣. សហចៅក្រមស៊ើបអង្កេត បានទទួលស្គាល់ថា "ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋកម្មទាំងឡាយដែលជនត្រូវចោទកំពុងតែស្ថិតនៅក្នុងការស៊ើបអង្កេតនោះ គឺមិនមែនជាឧបសគ្គដោយផ្ទាល់ដែលរារាំងចំពោះការដោះលែងនោះទេ ។ ទោះជាយ៉ាងណាក្តី កត្តានេះគឺមានការជាប់ទាក់ទងគ្នានៅក្នុងការប៉ាន់ស្មានវាយតម្លៃអំពីលក្ខណៈវិនិច្ឆ័យ ដើម្បីសម្រេចទៅលើការបន្តការឃុំខ្លួន និងអំពីភាពស្របច្បាប់នៃការសម្រេចនេះ" ។ សេចក្តីថ្លែងនេះ គឺស្របគ្នាទៅនឹងយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិដែលក្នុងនោះរួមបញ្ចូលទាំងប្រភេទនៃបទល្មើសដែលបានចោទប្រកាន់ផងសម្រាប់ធ្វើជាលក្ខណៈវិនិច្ឆ័យមួយ ដើម្បីធ្វើតេស្តសាកល្បង ក្នុងការសម្រេចអំពីភាពសមហេតុសមផលនៃការឃុំខ្លួនបណ្តោះអាសន្ន[93] ។ មេធាវីការពារក្តីគ្រាន់តែសំដែងការមិនយល់ស្របចំពោះសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ និងព្យាយាមធ្វើមិនដឹងមិនឮចំពោះការយល់ឃើញដ៏ត្រឹមត្រូវ ដែលសហចៅក្រមស៊ើបអង្កេតបានផ្តល់ទៅលើ ស្ថានការណ៍នៃករណីរឿងតែប៉ុណ្ណោះ ហើយនឹងដាក់យោបល់ឃើញរបស់ខ្លួនជាជំនួសឱ្យការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតវិញ ។ លើសពីនេះមេធាវីការពារក្តីបានធ្វើការតវ៉ា ទាមទារដោយភាន់ច្រឡំថា សហចៅក្រមស៊ើបអង្កេតបានខកខានមិនបានពិចារណាអំពីវិធាន ការនានាសម្រាប់ជាជំនួសឱ្យការឃុំខ្លួនជាបណ្តោះអាសន្ន ដោយផ្អែកលើមូលដ្ឋាននៃស្ថានទម្ងន់

---

[92] បណ្តឹងឧទ្ធរណ៍, C40/5/1, កថាខណ្ឌទី៣/២៣ ។

[93] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Tihomir Blaskic,* ដីកាសម្រេចបដិសេធលើញត្តិស្នើសុំដោះលែងបណ្តោះអាសន្ន, សំណុំរឿងលេខ IT-94-14, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី២០ ធ្នូ ១៩៩៦ (C20/3, ប្រភពច្បាប់ 3) ។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Mrda,* ដីកាសម្រេចលើសំណើរបស់ Darko Mrda ដែលស្នើសុំដោះលែងបណ្តោះអាសន្ន, សំណុំរឿងលេខ IT-02-59-PT, អង្គជំនុំជម្រះសាលាដំបូងទីII នៃតុលាការ ICTY , ចុះថ្ងៃទី១៥ មេសា ២០០២ (C11/11, ប្រភពច្បាប់ C19) ។

ទោសនៃបទចោទតែមួយគត់តែប៉ុណ្ណោះ ។ តាមពិតសហចៅក្រមស៊ើបអង្កេតបាន សម្រេចថា គ្មានវិធានការណ៍ណាផ្សេងពីនេះដែលសមស្របនោះទេ ដោយយល់ឃើញថាតាមជាក់ស្តែង លក្ខខណ្ឌតម្រូវភាគច្រើននៅក្នុងវិធាន ៦៣.៣.ខ ត្រូវបានបំពេញគ្រប់គ្រាន់ហើយ[94] ។ នៅក្នុងកាលៈទេសៈដូចនេះ ដែលលក្ខខណ្ឌតម្រូវទាំងឡាយសម្រាប់ការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានបំពេញគ្រប់គ្រាន់ហើយនោះ យុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិមិនអនុញ្ញាតឱ្យធ្វើការពិចារណាដោយផ្អែកទៅលើស្ថានទម្ងន់ទោសនៃបទល្មើស ដែលបានចោទប្រកាន់ដើម្បីនឹងធ្វើការសម្រេចថា តើការឃុំខ្លួនបណ្ដោះអាសន្នជាការចាំបាច់ ឬមិនចាំបាច់នោះទេ[95] ។

៣៤. ចំណែកលក្ខខណ្ឌតម្រូវផ្សេងៗដែលសម្រាប់ជាជំនួស នៃវិធាន៦៣.៣.ខ នៃវិធានផ្ទៃក្នុងវិញ សហព្រះរាជអាជ្ញា បានដាក់បញ្ចូលដោយយោងទៅលើសេចក្ដីសន្និដ្ឋានដូចដែលមាននៅក្នុងកថាខណ្ឌពីទី៥៣ ដល់ទី៧៣ នៃ "ចម្លើយតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន[96] និង កថាខណ្ឌពីទី១៥ ដល់ទី២៥ នៃចម្លើយតបរបស់ខ្លួនទៅនឹងដីកាបញ្ជូនរឿងឱ្យពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតស្ដីពីពាក្យសុំដោះលែងជាបន្ទាន់របស់ខៀវ សំផន ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៨[97]" ។ សហព្រះរាជអាជ្ញា ក៏បានយោងផងដែរទៅលើដីកាបដិសេធការដោះលែងរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨, កថាខណ្ឌទី១៥-២១[98] ។

---

[94] ដីកាបដិសេធការដោះលែង, C40/4, កថាខណ្ឌទី២៥ ។

[95] *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង Sesay et al.,*, ដីកាសម្រេចលើញត្តិដែលដាក់ជូនដោយ Morris Kallon ដែលស្នើសុំដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ,សំណុំរឿងលេខ SCSL-04-15-PT, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការពិសេស សម្រាប់ប្រទេស Sierra Leone, ចុះថ្ងៃទី២៣ កុម្ភៈ ២០០៤, កថាខណ្ឌទី៣៤ (C11/11, ប្រភពច្បាប់ C42): " ពាក្យសុំដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ តម្រូវឱ្យពិនិត្យមើលឡើងវិញឱ្យបានដិតដល់ និងការពិចារណាដោយយកចិត្តទុកដាក់ទៅតាមលក្ខខណ្ឌតម្រូវនានានៃវិធាន៦៥...ក្នុងការធ្វើដូចនេះគេត្រូវតែចងចាំនៅក្នុងចិត្តថា នៅក្នុងប្រភេទជាក់លាក់របស់តុលាការអន្តរជាតិនានាឧក្រិដ្ឋកម្មទាំងឡាយដែលតុលាការបែបនេះមានយុត្តាធិការទៅលើ អាចត្រូវបានចាត់ទុកថា ជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរជាងគេបំផុតដែលស្ថិតក្រោមច្បាប់អន្តរជាតិ ។ អាស្រ័យហេតុនេះ អាចនិយាយបានថា វិធីសាស្ត្រក្នុងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ ដែលគេប្រើភាគច្រើននៅតាមតុលាការជាតិនានា អាចនឹងខុសគ្នាពីវិធីសាស្ត្រសម្រាប់តុលាការអន្តរជាតិណាមួយតួយ៉ាងដូចជាតុលាការពិសេស" ។

[96] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៩ វិច្ឆិកា ២០០៧, ថ្ងៃទី៦ កុម្ភៈ ២០០៨, C26/1/9, ERN 00160767-95 (ភាសាអង់គ្លេស) ។

[97] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា ទៅនឹង ដីកាបញ្ជូនរឿងឱ្យពិនិត្យរបស់ សហចៅក្រមស៊ើបអង្កេត ស្ដីពីពាក្យសុំដោះលែងជាបន្ទាន់របស់ ខៀវ សំផន, ចុះថ្ងៃទី២៤ តុលា ២០០៨, C40/3, ERN 00234631-45 (ភាសាអង់គ្លេស) ។

[98] ដីកាសម្រេចបដិសេធការដោះលែង, C40/4 ។

៣៥. ជាបន្ថែមពីលើនេះ សហព្រះរាជអាជ្ញា សន្និដ្ឋានថាធាតុផ្សំថ្មីៗមួយចំនួនដែលផ្ទុយទៅនឹងទឡ្ហីករណ៍ទាំងឡាយដែលបានលើកឡើងដោយមេធាវីការពារក្ដីនៅក្នុងបណ្ដឹងឧទ្ធរណ៍ ។

*វិធាន៦៣.៣.ខ.១-ការគាបសង្កត់ទៅលើសាក្សី និងជនរងគ្រោះនានា*

៣៦. មេធាវីការពារក្ដីបានលើកឡើងតវ៉ាថា សហចៅក្រមស៊ើបអង្កេតបានខកខានមិនបានបង្ហាញភស្តុតាងអំពីសកម្មភាព ឬ អាកប្បកិរិយារបស់ជនត្រូវចោទកាលពីអតីតកាល ដែលជាការបង្ហាញឱ្យឃើញអំពីហានិភ័យជាក់ស្ដែងមួយថា ជនត្រូវចោទអាចធ្លាប់បានប្រើប្រាស់ឥទ្ធិពលនោះដើម្បីធ្វើការគាបសង្កត់ទៅលើសាក្សីនោងជនរងគ្រោះនានា[99] ។ សហមេធាវីការពារក្ដីបានច្រានចោលនូវភស្តុតាង ដែលបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេតដើម្បីគាំទ្រចំពោះសេចក្ដីសន្និដ្ឋានរបស់ខ្លួនលើចំណុចនេះ[100] ។ តុលាការ ICTY បានថ្លែងថា បើសិនជាអង្គជំនុំជម្រះសាលាដំបូងមិនបានចាត់នូវរាល់វិធានការណ៍នានាដែលចាំបាច់ដើម្បីធានាចំពោះសាក្សីទាំងឡាយដែលផ្ដល់សក្ខីកម្មនៅចំពោះមុខតុលាការទេនោះ គឺវាមុខជានឹងធ្វើឱ្យខូចដល់សុច្ចរិតភាពនៃការជំនុំជម្រះក្ដីហើយ និងថា ការថយចុះនៃចំនួនសាក្សីដែលមានចេតនាចង់មកផ្ដល់សក្ខីកម្មនៅក្នុងករណីរឿងក្ដីណាមួយនោះ គឺវានឹងធ្វើឱ្យខូចដល់មុខងារដ៏សំខាន់ជាង គេបំផុតរបស់អង្គជំនុំជម្រះសាលាដំបូងហើយ គឺបានន័យថា មុខងារក្នុងការរកឱ្យឃើញការពិត[101] ។

៣៧. ស្ថានការណ៍ផ្សេងៗនៃករណីរឿងក្ដីនាពេលបច្ចុប្បន្ននេះ មានដូចខាងក្រោមនេះ៖ ក) មានសាក្សីជាគន្លឹះតែមួយចំនួនតូចប៉ុណ្ណោះ ដែលនៅរស់រានមានជីវិតអស់រយៈពេល៣០ឆ្នាំមកហើយ ក្រោយពីរបបប៉ុលពតត្រូវបានបញ្ចប់ ។ ខ) ការមានអារម្មណ៍ភ័យខ្លាចជាលក្ខណៈ

---

[99] បណ្ដឹងឧទ្ធរណ៍, C40/5/1, កថាខណ្ឌទី៥២។

[100] ដីកាសម្រេចបដិសេធការដោះលែង, C40/4, កថាខណ្ឌទី១៦, លេខយោងជើងទំព័រលេខ២០: " មេៗដឹកនាំខ្មែរទាំងឡាយចង់ឱ្យមានគណៈកម្មការស្វែងរកការពិត ជាជំនួសឱ្យសវនាការជំនុំជម្រះក្ដីវិញ", អត្ថបទនៃសារព័ត៌មាន *Agence France Press*, ចុះថ្ងៃទី១ ធ្នូ ២០០២ (D29, ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់លេខ៧៤) ។

[101] *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង Haradinaj,* ដីកាសម្រេចលើញត្តិស្នើសុំដែលធ្វើក្នុងនាម Ramush Haradinaj ដែលសុំ ឱ្យដោះលែងបណ្ដោះអាសន្ន, សំណុំរឿងលេខ IT-04-84-T, អង្គជំនុំជម្រះទី១នៃសាលាដំបូង នៃតុលាការ ICTY, ចុះថ្ងៃទី២០ កក្កដា ២០០៧ (C20/I/7, ប្រភពច្បាប់ B27) ។

ទូលំទូលាយមិនបានផ្តល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក ដោយផ្អែកលើការព្រួយបារម្ភក្រែង មានការសងសឹក ឬ ការបំភិតបំភ័យ[102] ។ គ) អវត្តមាននៃវិធានការសម្រាប់ការពារសាក្សី នៅក្នុងពេលបច្ចុប្បន្ន ។ ដោយមានការយល់ឃើញចំពោះស្ថានការណ៍ទាំងនោះ ការគំរាមកំហែងអំពីការសងសឹកតបវិញ ដែលធ្វើឡើងដោយជនត្រូវចោទចំពោះជនទាំងឡាយ ទាក់ទងអំពីការយកពួកមេដឹកនាំរបស់ខ្មែរក្រហមទៅកាត់ទោស គួរតែត្រូវបានចាត់ទុកថាជាភស្តុតាងមួយស្តីពីជនជាប់ចោទបានមាននិន្នាការធ្វើការរារាំងដល់ដំណើរការរបស់តុលាការ[103] ។ ការគំរាមកំហែងទាំងនោះ គួរតែត្រូវបានចាត់ទុកថា ជាទម្ងន់បន្ថែមដោយសារតែលទ្ធផលនៃការគាំទ្រដល់ជនត្រូវចោទ ដែលនៅតែមានជាបន្តទៅទៀត នៅក្នុងផ្នែកមួយខ្លះនៃប្រទេសនៅឡើយ[104] ហើយនិងឥរិយាបថចំពោះដំណើរការនីតិវិធីនៅក្នុង អ.វ.ត.ក របស់ពួកអ្នកដែលគាំទ្ររូបគាត់មួយចំនួន[105] ។ ជាការច្បាស់លាស់ណាស់ថា មេធាវីការពារក្តីបានធ្វើឱ្យការយល់ឃើញទាំងនោះលែងមាន សារៈសំខាន់ដូចមុន និងបានធ្វើឱ្យងងិតមើលលែងឃើញអំពីស្ថានទម្ងន់ទោសដែលមាននៅ ក្នុងការមានមតិកត់សំគាល់របស់ជនត្រូវចោទ ដែលបានធ្វើការព្រានចោលដោយភាន់ច្រឡំនូវការរកឃើញរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីហានិភ័យ

---

[102] អត្ថបទរបស់លោក Geerteke Jansen, *សម្លេងពីខេត្តតាកែវ: ការវាយតម្លៃសាកល្បងអំពីការភ័យខ្លាចរបស់សាក្សីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា,* នៃមជ្ឈមណ្ឌលឯកសារកម្ពុជា, ចុះខែតុលា ឆ្នាំ២០០៦ (D29, ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់ លេខ ៨០) ។

[103] "មេៗដឹកនាំខ្មែរទាំងឡាយចង់ឲ្យមានគណៈកម្មការស្វែងរកការពិត ជាជំនួសឲ្យសវនាការជំនុំជម្រះក្តីវិញ", អត្ថបទនៃសារព័ត៌មាន *Agence France Press,* ចុះថ្ងៃទី១ ធ្នូ ២០០២ (D29, ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់លេខ៧៤) ។

[104] សូមអាន "ការវិភាគ-សមមិត្តៗដែលត្រូវបានគេមើលឃើញថា ការពារមេដឹកនាំខ្មែរក្រហម", David Bronnstrom, សារព័ត៌មាន Reuters, ចុះថ្ងៃទី៤ មករា ១៩៩៩ (D29, ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់លេខ ៦៩) ។ "មូលដ្ឋានបង្អែកដ៏រឹងមាំរបស់អតីតខ្មែរក្រហមបានក្លាយទៅជាស្ថានសួគ៌សុវត្ថិភាពសម្រាប់ពួកមេដឹកនាំ", Don Pathan, សារព័ត៌មាន Associated Press Newswires, ចុះថ្ងៃទី៩ មករា ១៩៩៩ (D29, ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់លេខ ៧០) ។ "ពួកមេដឹកនាំខ្មែរក្រហម នៅភាគខាងជើងនៃប្រទេសកម្ពុជា": ប្រភពព័ត៌មានពីថៃ, មេដឹកនាំចលនាឥស្សិ", សារព័ត៌មាន *Agence France-Press,* ១៣ មិថុនា ១៩៩៨ (D29, ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់លេខ ៧១) ។ "មេដឹកនាំខ្មែរក្រហមចាកចេញទៅកាន់ទីក្រុងភ្នំពេញដើម្បីចរចា, សារព័ត៌មាន Reuters News, ចុះថ្ងៃទី ២៨ ធ្នូ ១៩៩៨ (D29, ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់លេខ ៧៣) ។ "មេដឹកនាំខ្មែរក្រហម ប្រឆាំងជំទាស់ទៅនឹងការអំពាវនាវឲ្យមាន ការជំនុំជម្រះក្តី", សារព័ត៌មាន *Agence France-Press,* ចុះថ្ងៃទី១ មករា ១៩៩៩ (D29, ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់លេខ ៧៣) ។

[105] សូមអាន ២០ឆ្នាំមកហើយដែលខ្មែរក្រហមនៅតែគំរាមថា នឹងមានសង្គ្រាមទៀត, សារព័ត៌មាន Agence France-Press, ចុះថ្ងៃទី៧ មករា ១៩៩៩ ដែលនៅក្នុងអត្ថបទនោះ អភិបាលក្រុងប៉ៃលិនឈ្មោះ អ៊ី ឈាន ត្រូវបានគេរាយការណ៍មកថា ការប៉ុនប៉ងណាមួយដើម្បីនាំខ្លួន ខៀវ សំផន ឬ នួន ជា ជាលទ្ធផលគឺនឹងធ្វើឲ្យមានសង្គ្រាមស៊ីវិល (D29, ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់លេខ ៧៥) ។

00275500

C40/5/2



ជាក់ស្តែងនៃការជ្រៀតជ្រែកចំពោះជនរងគ្រោះ និងសាក្សីនានាដែលកើតចេញពីសកម្មភាពកាលពីអតីតកាលរបស់ជនត្រូវ ចោទ និងឥទ្ធិពលរបស់គាត់នៅក្នុងពេលសព្វថ្ងៃ ។

៣៨. អាស្រ័យដោយមូលហេតុទាំងនេះ សហព្រះរាជអាជ្ញា បានយល់ស្របជាមួយសហចៅក្រមស៊ើបអង្កេតថា (១) ពេលវេលាដែលបានកន្លងផុតទៅនៃចាប់តាំងពីការឃុំខ្លួនជនត្រូវចោទមកនោះមិនបានធ្វើឱ្យហានិភ័យថយចុះ ឬត្រូវបានលុបបំបាត់អស់នោះទេ ក៏ប៉ុន្តែផ្ទុយទៅវិញគឺរឹតតែធ្វើឱ្យមានសភាពកាន់តែធ្ងន់ធ្ងរឡើងថែមទៀត ។ (២) ថា ខៀវ សំផន អាចមានសិទ្ធិក្នុងការពិនិត្យមើលសំណុំរឿងបាន និងថា នៅក្នុងសំណុំរឿងនោះមាន "កំណត់ហេតុស្តាប់ចម្លើយសាក្សីនានា ក៏ដូចជាមានពាក្យបណ្តឹងផ្សេងៗ ហើយនិងពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី" ។ (៣) ថា មាន "ហានិភ័យពិតប្រាកដថាសាក្សីទាំងឡាយអាចនឹងប្រកែកមិនព្រមចូលរួមនៅក្នុងដំណើរការនីតិវិធីនៅក្នុងពេលអនាគត"។ និង(៤)ថាមានមូលហេតុផ្សេងៗដែលធ្វើឱ្យជឿថា សាក្សីទាំងនោះអាចនឹងត្រូវស្ថិតក្រោមការគាបសង្កត់ ដោយសារតែពួកគេធ្លាប់ជាមនុស្សនៅក្រោមបង្គាប់របស់ជនត្រូវចោទ ឬ មួយក៏ក្នុងន័យទូលំទូលាយជាងនេះទៅទៀតនោះគឺ ពីព្រោះតែមុខតំណែងជាន់ខ្ពស់ទាំងអស់ ដែលជនត្រូវចោទធ្លាប់បានកាន់កាប់នោះ"[106] ។

## *វិធាន៦៣.៣.៤-ការពារសន្តិសុខដល់ជនត្រូវចោទ*

៣៩. ចំពោះការគំរាមកំហែងដែលបង្កឡើងចំពោះសន្តិសុខផ្ទាល់ខ្លួនរបស់គាត់- វិធាន៦៣.៣.ខ.៤ - មានសេចក្តីថ្លែងការណ៍ថ្មីៗនេះ និងអាកប្បកិរិយារបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន បានបង្ហាញឱ្យឃើញថា ការដោះលែងជនណាម្នាក់ក្នុងចំណោមជនត្រូវចោទទាំងប្រាំ(៥) រូបនេះ អាចនឹងធ្វើឱ្យប្រែក្លាយទៅជាអំពើហិង្សាសំដៅប្រឆាំងចំពោះអតីតមេដឹកនាំខ្មែរក្រហមទាំងនោះ រួមទាំងដើមបណ្តឹងឧទ្ធរណ៍, ក្រុមមេធាវីការពារក្តី ឬអ.វ.ត.ក ផង ។ នៅក្នុងអត្ថបទមួយដែលចុះផ្សាយនៅក្នុងកាសែត The New York Times បានសរសេរថា

---

[106] ដីកាសម្រេចបដិសេធការដោះលែង, C40/4, កថាខណ្ឌទី១៥-១៦ ។

កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨[107] មានជនរងគ្រោះពីរនាក់បាននិយាយថា ពួកគេរៀងៗខ្លួន ចង់តែ "ហាន់ (នួន ជា) ឱ្យទៅជាជំរៀកៗ ហើយរោយអំបិលទៅលើស្នាមរបួស របស់គាត់ (...) វាយដំគាត់ និង ធ្វើទារុណកម្មគាត់ ហើយនិងដាក់គាត់ឱ្យខ្សែភ្លើងឆក់ដើម្បីធ្វើឱ្យគាត់ឆ្លើយ" ហើយឱ្យពួកគាត់ (ជនត្រូវចោទ) "ទទួលរងនូវការឈឺចាប់ដូចកាលពីពេលខ្ញុំឈឺចាប់នោះដែរ" ដូចជា "ទាល់តែសម្លាប់គាត់ នោះទើបធ្វើឱ្យខ្ញុំស្ងប់ចិត្ត" ។ មានមនុស្ស ៣នាក់បានពោលឡើងវិញដដែលៗនូវសំដី/ពាក្យគម្រាមកំហែងទាំងនោះ (ដែលមិនគ្រាន់តែប្រឆាំងនឹង ខៀវ សំផន និងក្រុមមេធាវីការពារក្តីរបស់គាត់តែប៉ុណ្ណោះទេ ក៏ប៉ុន្តែប្រឆាំងនឹងតុលាការផងដែរ) នៅក្នុងពេលសន្និសីទសារព័ត៌មានមួយដែលធ្វើឡើង បន្ទាប់ពីសវនាការរបស់ អ.ប.ជ កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨[108] ។ ការសំដែងប្រតិកម្មដោយការរំជើបរំជួលក្នុងចិត្តទាំងនេះ

---

[107] "នៅក្នុងសវនាការជំនុំជម្រះក្តីខ្មែរក្រហម ជនរងគ្រោះនឹងមិនមែនចូលរួមទ្រទ្រង់ដោយឥតបានការនោះទេ", The New York Time, Seth Mydans, ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨, អាចរកមើលបានតាមរយៈវិបសាយ: http://www.nytimes.com/06/2008/17/world/asia/17cambodia.html?scp=1&sq=Seth%20Mydans%20in%20Khmer%20Rouge%20Trial%20Victims&st=cse ដែលបានបើកចូលកាលពីថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩ (C20/5/7.7) ។

[108] តាមក្នុងខ្សែអាត់វីឌីអូ របស់ អ.វ.ត.ក ស្តីពីសន្និសិទសារព័តមាន ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ (ដែលបង្ហាញជូន តាមរយៈឯកសារ **C20/5/7.8R** នៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធិរិទ្ធ ប្រឆាំងនឹងដីកាសម្រេចស្តីពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៩ មករា, ERN 00270535) បានបង្ហាញឱ្យឃើញថា មានស្ត្រីជាជនរងគ្រោះទីមួយ នៃរបបខ្មែរក្រហមម្នាក់ (ដែលត្រូវបានរាយការណ៍មកថា ឈ្មោះ ស៊ុត នី) បានស្រែកគំហក និងចង្អុលដាក់សហមេធាវីការពារក្តីខ្មែរ នៅក្នុងពេលសន្និសិទសារព័តមាន ។ លី មុន្នីសារ (Ly Monysar) ជនរងគ្រោះ ដែលឥឡូវនេះ ជាឆ្នាំសន្តិសុខ បានគំរាមកំហែងតុលាការថានឹងធ្វើសកម្មភាពភេរវកម្មមួយប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមទាំងនោះ "ប្រសិនបើតុលាការនៅតែបន្តធ្វើជាឆាក ល្ខោនតទៅទៀតនោះ" នៅក្នុងពេលសន្និសិទសារព័តមានរបស់ជនរងគ្រោះ ហើយនិងស្ត្រីជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ (អ្នកដាក់ពាក្យ សុំ) ឈ្មោះ សុខ ជា បាននិយាយសារចុះសារឡើងថា បើសិនជាគាត់អាចចាប់ ខៀវ សំផន បាននោះ គាត់ចង់ "ស្ទុះទៅ ហែកស៊ី ទាំងរស់" ។ សូមមើលផងដែរ "តុលាការខ្មែរក្រហម: l'exaspération des victims intensifiée par un clash avec la défense" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០០៨, Ka-Set (site d'information sur le Cambodge), Stéphanie Gée, ដែល អាច រកមើលបាននៅ ក្នុងវិបសាយ ដែលមានអាសយដ្ឋានដូចខាងក្រោមនេះ : http://ka-set.info/index2.php?option=com_content&task=view&id=783&pop=1&page=0&Itemid=46 (**C20/5/7.9**); "មានរឿងកំប្លុកកំប្លែងជួបយុត្តិធម៌នៅក្នុងសវនាការកាត់ក្តីខ្មែរក្រហម" *The Nation* (New York, USA), Barbara Crossette, ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨, កថាខ័ណ្ឌទី៤ (**C20/5/7.10**); (**ឧបសម្ព័ន្ធ ខ - ឯកសារភ្ជាប់ លេខ៥**) ។ "តុលាការខ្មែរក្រហមបើកសវនាការលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេច ស្តីពីករណីបកប្រែសំណុំរឿង", ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, ច្បាប់បកប្រែជាភាសាអង់គ្លេស, *កាសែតរស្មីកម្ពុជា*, វ៉ុល១៦ លេខ៤៧៦០ (**C20/5/7.11**) ។ "ភាពគ្មានសណ្តាប់ធ្នាប់នៅក្នុងតុលាការ ខណៈដែលសវនាការបានបញ្ចប់នៅក្នុងភាពច្របូកច្របល់" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, អត្ថបទកាសែត *The Phnom Penh Post*, ដោយ Georgia Wilkins (**C20/5/7/12**) ។ "Le Cirque Vergès" ចុះថ្ងៃទី១១-១៧ ធ្នូ ២០០៨, កាសែត *Cambodge Soir*, ដោយ Adrien Le Gal ។ កម្រងអត្ថបទ កាសែតទាំង៤នេះ អាចបើករកមើលបាននៅក្នុង G:Drive របស់ អ.វ.ត.ក ទៅតាមកាលបរិច្ឆេទនៃការបោះផ្សាយរបស់កាសែតនីមួយៗ (G:\Public Affairs\Daily Clipping

គឺជារោគសញ្ញានៃជម្ងឺតានតឹងខាងផ្លូវអារម្មណ៍ ក្រោយមានការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរខាងផ្លូវចិត្ត ដែលនៅតែមានជាបន្តនៅឡើយក្នុងចំណោមជនរងគ្រោះ ដោយដំណើរការនៃនីតិវិធីរបស់ អ.វ.ត.ក បាននាំឱ្យមានការលេចឡើងជាថ្មីនូវការតានតឹងនៅក្នុងអារម្មណ៍[109] ។ អាស្រ័យហេតុនេះ ការគំរាមកំហែងជាសក្តានុពលចំពោះសន្តិសុខផ្ទាល់ខ្លួនរបស់ជនត្រូវចោទគឺ មិនមែនជាការគិតច្រឡំនោះទេ ក៏ប៉ុន្តែនៅតែមានភាពខ្លាំងក្លា និងជាក់ស្តែងនៅឡើយ ។

*វិធាន៦៣.៣.ខ.៥-រក្សាសណ្តាប់ធ្នាប់សាធារណៈ*

៤០. ជាងនេះទៅទៀត នៅពេលដែលមេធាវីការពារក្តីចោទថា សហចៅក្រមស៊ើបអង្កេតបានខកខានមិនបានបង្ហាញអង្គហេតុផ្សេងៗអំពីថា ដើមបណ្តឹងឧទ្ធរណ៍មុខជានឹងធ្វើការរំខានដល់សណ្តាប់ធ្នាប់សាធារណៈក្នុងពេលបច្ចុប្បន្នជាពុំខាន ទោះបីជាយ៉ាងណាក៏ពួកគេ បានយល់ស្របថា ការសម្រេចណាមួយអំពីបញ្ហាមានហានិភ័យចំពោះសណ្តាប់ធ្នាប់សាធារណៈចាំបាច់ត្រូវតែតម្រូវឱ្យមានវិធានការក្នុងការព្យាករណ៍ទុកជាមុនដែរ[110] ។

៤១. មេធាវីការពារក្តីបានប្រកែកតវ៉ាថា សហចៅក្រមស៊ើបអង្កេតគ្រាន់តែបានសម្រេចជោគជ័យនៅក្នុងការបង្ហាញភស្តុតាងឱ្យឃើញពីទុក្ខព្រួយ ដែលនៅតែមានជាបន្តនៅក្នុងចំណោមជនរងគ្រោះនៃរបបខ្មែរក្រហមតែប៉ុណ្ណោះ ដែលផ្ទុយទៅនឹងការជាក់ស្តែងដែលថា បើដោះលែងនោះគឺវាអាចនឹងធ្វើឱ្យខូចដល់សណ្តាប់ធ្នាប់សាធារណៈក្នុងពេលបច្ចុប្បន្នប៉ុណ្ណោះ។ មេធាវីការពារក្តីគ្រាន់តែធ្វើការច្រានចោលនូវភស្តុតាងដែលលើកឡើង ដោយសហចៅក្រមស៊ើបអង្កេតដែលបង្ហាញអំពីអង្គហេតុទាំងនេះតែប៉ុណ្ណោះ និងដើម្បីដាក់ជំនួសដោយមតិផ្ទាល់របស់ខ្លួនវិញទៅ

---

International\12.Dec) ។ "តុលាការខ្មែរក្រហម អំពីប្រល័យពូជសាសន៍ជិតប់ជើងចង់ដួលដោយសារមេធាវីការពារក្តីបារាំង ស្នើសុំឱ្យបកប្រែថ្មី", *Law.com:International News, ដោយលោក Claire Duffett, ចុះថ្ងៃទី១០ ធ្នូ ២០០៨* (ភ្ជាប់មកជាមួយ ឧបសម្ព័ន្ធ ខ, ឯកសារភ្ជាប់លេខ B1) ។

[109] Rob Savage និយាយថា ការចាប់ផ្តើមសកម្មភាពតុលាការនៅចំពោះមុខ អ.វ.ត.ក "អាចធ្វើឱ្យមានហានិយភ័យថ្មីៗចំពោះសង្គមកម្ពុជា" ដែលអាច "នាំឱ្យមានការលេចឡើងជាថ្មីនូវការចប់នៅក្នុងអារម្មណ៍ និងផលវិបាកសង្គមជាអវិជ្ជមាន ដែលអាចនឹងអមមកជាមួយនឹងសកម្មភាពទាំងនោះ"។ Rob Savage "ជម្ងឺតានតឹងខាងផ្លូវអារម្មណ៍ក្រោយមានការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរខាងផ្លូវចិត្តៈ មរតកនៃការឈឺចាប់ និងអំពើហិង្សាដែលបានបន្សល់ទុក", កាសែត *South Eastern Globe* ប្រចាំខែ, ខែកក្កដា ឆ្នាំ២០០៧, ទំព័រ ២៤-២៧, ERN 00153657-61 (ភាសាអង់គ្លេស) (C11/11, ឯកសារភ្ជាប់ ក) ។

[110] បណ្តឹងឧទ្ធរណ៍, C40/5/1, ទំព័រ៦០ ។

លើភស្តុតាងនេះជួសឲ្យការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត[111] ។ ភស្តុតាងរបស់អ្នកជំនាញដែលត្រូវបានមេធាវីការពារក្តីច្រានចោលនោះ ត្រូវបានសហចៅក្រមស៊ើបអង្កេត និង អង្គបុរេជំនុំជម្រះ យកមកពឹងផ្អែកដោយស្របគ្នា[112] ។ ដែលភស្តុតាងនោះបាននិយាយថា មានប្រជាជនកម្ពុជាចំនួន៣០% កំពុងតែទទួលរងនូវជម្ងឺតានតឹងខាងផ្លូវអារម្មណ៍ ក្រោយពីមានការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរខាងផ្លូវចិត្តនៅឡើយ ដែលបណ្តាលមកពីឧក្រិដ្ឋកម្មមានលក្ខណៈជាប្រព័ន្ធ និងទូលំទូលាយ កាលពីក្នុងអម្លុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ស្របតាមនេះ ដោយសារតែមានដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដែលជនសង្ស័យកំពុងត្រូវបានធ្វើការជំនុំជម្រះក្តីជា លើកដំបូងបង្អស់ចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅក្នុងអម្លុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ វាហាក់បីដូចជាមេធាវីការពារក្តីលើកឡើងតវ៉ាដោយមិនបានប្រុងប្រយ័ត្នថា បញ្ហាស្តីពីការតានតឹងនៅក្នុងអារម្មណ៍ និងសណ្តាប់ធ្នាប់សាធារណៈ ដែលបើទទួលយកមួយណាគឺត្រូវតែទាត់ចោលមួយទៀត ។ ចំណងតភ្ជាប់គ្នារវាងការតានតឹងនៅក្នុងអារម្មណ៍ដែលនៅតែមានជាបន្ត និងហានិភ័យចំពោះសណ្តាប់សាធារណៈ ត្រូវបានបញ្ជាក់ច្បាស់ក្នុងលក្ខណៈអាចផ្ទុះឡើង ដែលក្នុងនោះការសង្កត់ធ្ងន់បែបនេះ ត្រូវបានស្តែងចេញកាលពីពេលធ្វើសន្និសីទសារព័ត៌មានមួយ កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ (សូមអានកថាខណ្ឌទី៩ ខាងលើ) ។

៤២. មេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេត បានខកខានមិនបានបង្ហាញភស្តុតាងឲ្យឃើញអំពីភាពផុយស្រួយនៃសង្គមកម្ពុជានោះទេ ។ មេធាវីការពារក្តីបានឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋាននេះដោយផ្អែកលើមូលដ្ឋានអរូបី និង ដោយគ្មានការចង្អុលបង្ហាញភស្តុតាងនៅលើការដកស្រង់ខ្លីៗពីរបាយការណ៍នានា ដែលមិនការពាក់ព័ន្ធទៅនឹងបញ្ហាភាពផុយស្រួយនៃសង្គម និងអំពើហិង្សានៅក្នុងប្រទេសកម្ពុជា[113] នោះទេ ។ ការអះអាងរបស់មេធាវីការពារ

[111] បណ្តឹងឧទ្ធរណ៍, C40/5/1, ទំព័រ៦4 ។

[112] ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌុច ស្តីពីការឃុំខ្លួន, C5/45, លេខយោងជើងទំព័រ លេខ១០ និងលេខ២២ ។ ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ស្តីពីការឃុំខ្លួន, C5/I/27, លេខយោងជើងទំព័រ លេខ៣៦ និងលេខ៤៤ ។

[113] "របាយការណ៍ឆ្នាំ២០០៧ ស្តីពីការអភិវឌ្ឍន៍ធនធានមនុស្ស: ការពង្រីកជម្រើសឲ្យបានទៅដល់ប្រជាជននៅចុងកាត់មាត់ញក (NHDR)" ត្រូវបានលើកយកមកសំអាងនៅក្នុងបណ្តឹងឧទ្ធរណ៍ (C40/5/1) ត្រង់កថាខណ្ឌទី៦៩ ស្តីពីធនធានធម្មជាតិនានានិងជីវភាពរស់នៅតាមជនបទនៅក្នុងប្រទេសកម្ពុជា។ "ការបែងចែកកំណើន, សមធម៌ និងការអភិវឌ្ឍន៍ នៅក្នុងប្រទេសកម្ពុជា", របាយការណ៍នេះ

ក្ដីបានលើកយកមកបង្ហាញដោយមិនត្រឹមត្រូវ អំពីសភាពការណ៍បច្ចុប្បន្នរបស់កម្ពុជា ដូចដែលវិទ្យាស្ថានសេដ្ឋកិច្ច និងសន្តិភាព បានធ្វើការកំណត់នៅក្នុងឆ្នាំ២០០៨ថា មានភាវនីយភាពយ៉ាងខ្ពស់ថាមុខជានឹងមានបាតុកម្មដោយហឹង្សា, មានអំពើឧក្រិដ្ឋកម្មដោយហឹង្សាផ្សេងៗក្នុងកំរិតខ្ពស់និងមានអាវុធធុនតូចត្រៀមស្រាប់ដែលអាចងាយរកបាននៅក្នុងប្រទេសកម្ពុជា[114] ។ នៅក្នុងបរិបទនេះ ការដោះលែងជនណាម្នាក់ដែលត្រូវបានចោទប្រកាន់នៅក្នុងចំណោមមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ មុខជានឹងមានភាវនីយភាព ក្នុងការបណ្ដាលឱ្យមានប្រតិកម្មជាអវិជ្ជមានផ្សេងៗនៅក្នុងចំណោមប្រជាជន និងត្រូវបានគេយល់ឃើញថា គឺជាឧបសគ្គរាំងដ៏ធំមួយនៅក្នុងដំណើរការ ក្នុងការនាំខ្លួនមេដឹកនាំខ្មែរក្រហមទាំងនោះ ទៅឱ្យតុលាការជំនុំជម្រះក្ដីដែលគេបានទទ្ទឹងរង់ចាំជាយូរណាស់មកហើយ ។

៤៣. មេធាវីការពារក្ដីពឹងផ្អែកទៅលើករណីរឿងក្ដីរបស់ *រដ្ឋអាជ្ញា ទល់នឹង Haradinaj* ដើម្បីយកមកពោលអះអាងថា តុលាការដទៃៗទៀតគេបានអនុញ្ញាតឱ្យដោះលែងជនជាប់ចោទនានាទោះបីជាមានផលប៉ះពាល់ដ៏មានសក្ដានុពលទៅលើសណ្ដាប់ធ្នាប់សាធារណៈនោះក្ដី[115] ។ មេ

---

ក៏ត្រូវបានលើកជាសំអាងផងដែរនៅក្នុងបណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌទី៦៩ គឺពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចនៅកម្ពុជា ។ ឯកសារទាំងនេះមិនបានផ្ដល់នូវភស្តុតាងដែលផ្អែកតាមការពិសោធន៍ស្ដីពីស្ថេរភាព ឬភាពផុយស្រួយនៃសង្គមកម្ពុជានោះទេ ។

[114] វិទ្យាស្ថានសេដ្ឋកិច្ច និងសន្តិភាព បានចំណាត់ថ្នាក់ប្រទេសកម្ពុជា ជាប្រទេសដែលស្ថិតនៅក្នុងលំដាប់ថ្នាក់ទី៩១ ដែល មានសន្តិភាពជាងគេបំផុតក្នុងចំណោមប្រទេសចំនួន១៤០ ។ វិទ្យាស្ថានសេដ្ឋកិច្ចនិងសន្តិភាព, ការផ្ដួចផ្ដើមគំនិតដើម្បីសន្តិភាពពិភពលោក ឆ្នាំ២០០៨ ដែលអាចបើករកមើលបានក្នុងវិបសាយដែលមានអាសយដ្ឋាន: http://visionofhumanity.org/gpi/results/Cambodia/2008 (ភ្ជាប់មកជាមួយឧបសម្ព័ន្ធ ខ, ឯកសារភ្ជាប់ B2) ។ ការរកឃើញនេះគឺស្របគ្នានឹងពត៌មានដែលនៅក្នុងសំណុំរឿង ទាក់ទងទៅនឹងសក្ដានុពលនៃភាពចលាចលដល់សណ្ដាប់ធ្នាប់សាធារណៈ ដែលអាចនឹងកើតមានឡើងក្រោយពេលដោះលែងជនត្រូវចោទ ណាម្នាក់: "អាវុធត្រូវបានគេដុតបំផ្លាញចោលដើម្បីនឹងជួយកំចាត់ឱ្យអស់នូវកេរ្ដិ៍ដំណែលដ៏មានគ្រោះថ្នាក់ដល់អាយុជីវិត ដែលបានបន្សល់នៅកម្ពុជាពីរបបខ្មែរក្រហម",អត្ថបទសារពត៌មាន *Associated Press,* ចុះថ្ងៃទី៣០ មីនា ២០០៥ ដែលពីពណ៌នា អំពីពិធីដុតបំផ្លាញចោល នូវអាវុធចំនួន ៣៥០០ដើម កាំភ្លើងបាញ់គ្រាប់រ៉ុកកែត និងគ្រាប់រំសេវ ដែលជាផ្នែកនៅក្នុងការខិតខំប្រឹងប្រែងមួយ ក្នុងការលុបបំបាត់ឱ្យអស់នូវអាវុធដែលបានបន្សល់ទុកតាំងពីពេលជម្លោះ (ប្រដាប់អាវុធ) នៅកម្ពុជាមក (D29, ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់លេខ៧៦) ។ ក្រុមជំនួយជប៉ុនដើម្បីគ្រប់គ្រងអាវុធធុនតូចនៅកម្ពុជា "កំណត់ហេតុស្ដីពីការប្រមូលអាវុធ ឆ្នាំ២០០៥-២០០៧" (JSAC, 2007) (D29, ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់លេខ៧៧) ។ Christine Wille, "តើមានអាវុធប៉ុន្មាននៅក្នុងប្រទេសកម្ពុជា?" ឯកសារការងារស្ដីពីការស្ទង់មតិស្ដីពីអាវុធធុនតូចនៅកម្ពុជា (ការស្ទង់មតិស្ដីពីអាវុធធុនតូច ឆ្នាំ២០០៥) (D29, ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់លេខ៧៨) ។ "សេចក្ដីសង្ខេបសន្ទរកថារបស់លោក ថោ សារ៉ន ចៅក្រមខ្មែរ " នៅក្នុងអង្គសិក្ខាសាលាថ្នាក់ជាតិមួយ ស្ដីពីការលើកកំពស់ការយល់ដឹងអំពីច្បាប់គ្រប់គ្រងអាវុធ ពីថ្ងៃទី១៦ ដល់១៨ កក្កដា ២០០៦, ទំព័រ១៥-១៦ (ក្រុមការងារស្ដីពីការកាត់បន្ថយអាវុធ, ឆ្នាំ២០០៦) (D29, ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់លេខ៧៩) ។

[115] បណ្ដឹងឧទ្ធរណ៍, C40/5/1, កថាខណ្ឌទី៧០ ។

ធាវីការពារក្តីបានខកខានមិនបានថ្លែងថា សំណើសុំដោះលែងជាបណ្តោះអាសន្នបន្ទាប់មួយនេះ ដែលបានធ្វើឡើងដោយ Haradinaj នៅក្រោយថ្ងៃផុតកាលបរិច្ឆេទកំណត់នៃរយៈពេលដំបូងនៃការដោះលែងជាបណ្តោះអាសន្ន ត្រូវបានបដិសេធចោល ដោយសារតែមានបរិយាកាសពោរពេញទៅដោយការបំភិតបំភ័យនៅក្នុងសង្គមរបស់កូសូវ៉ូ ចំពោះសាក្សីទាំងឡាយនៅក្នុងតុលាការ ICTY [116] ទោះបីជាជននេះមានអាកប្បកិរិយាជាគំរូ នៅក្នុងពេលដោះលែងរូបគាត់ក្តី ។

៤៤. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើឲ្យ អង្គបុរេជំនុំជម្រះ សម្រេចថា មេធាវីការពារក្តីបានខកខានមិនបានធ្វើការគាំទ្រដល់ពាក្យសុំដោះលែងជាបណ្តោះអាសន្នរបស់ខ្លួនដោយការផ្តល់ភស្តុតាងដែលបង្ហាញឲ្យឃើញថា លក្ខខណ្ឌតម្រូវនានាសម្រាប់ឲ្យធ្វើការដោះលែងដែលស្ថិតនៅក្រោមវិធាន៦៣.៣.ខ.១, ២, ៤, និង៥ នោះ លែងត្រូវបានបំពេញគ្រប់គ្រាន់តទៅទៀតហើយ ។

*គ. មិនមានការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការទេ*

៤៥. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយ មិនអាចមានលក្ខណៈតឹងតែងគ្រប់គ្រាន់ដើម្បីអាចបំពេញបានគ្រប់ទៅតាមលក្ខខណ្ឌតម្រូវដែលចាំបាច់ ដើម្បីធានាការពារសុវត្ថិភាពរបស់ជនត្រូវចោទ, រក្សាសណ្តាប់ធ្នាប់សាធារណៈ, និងទប់ស្កាត់កុំឲ្យជនត្រូវ

---

[116] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Haradinaj,* ដីកាសម្រេច លើញត្តិស្នើសុំដែលធ្វើក្នុងនាម Ramush Haradinaj ដែលសុំឲ្យដោះលែងបណ្តោះអាសន្ន, សំណុំរឿងលេខ IT-04-84-T, អង្គជំនុំជម្រះទី១នៃសាលាដំបូង នៃតុលាការ ICTY, ចុះថ្ងៃទី២០ កក្កដា ២០០៧ (C20/I/7, ប្រភពច្បាប់ B27) ។ Hradinaj ត្រូវបាន អង្គជំនុំជម្រះទី១ នៃសាលាដំបូង នៃតុលាការ ICTY លើកលែងការចោទប្រកាន់ ក៏ប៉ុន្តែបញ្ហាស្ថិតនៅជាបញ្ហាដែលមានការប្រឆាំងតវ៉ាដដែល ដោយសារសាក្សីចំនួន២នាក់នៅក្នុងករណីរឿង ឈ្មោះ Sadri Selca nig Avni Krasniqi ត្រូវបានចោទប្រកាន់ពីប្រមាទពីបទមើលងាយតុលាការដោយសារខកខានមិនបានចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដោយមិនមានមូលហេតុត្រឹមត្រូវនិងដោយបដិសេធរឿងៗខ្លួនមិនព្រមផ្តល់សក្ខីកម្ម។ សូមអានសេចក្តីប្រកាសពត៌មានរបស់តុលាការ ICTY, ចុះថ្ងៃទី១៣ វិច្ឆិកា ២០០៧, "សាក្សីមួយរូបនៅក្នុងករណីរឿងរបស់ Haradinaj និងជនដទៃទៀត, ត្រូវបានចាប់ខ្លួនពីបទប្រមាថមើលងាយតុលាការ", ដែលអាបើករកមើលបាននៅក្នុងគេហទំព័រ: http://secnet069.un.org/sid/8825 ( ភ្ជាប់មកជាមួយឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់ A1) ។ ចាប់តាំងពីពេលនោះមកអយ្យការបានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍មួយដោយលើកឡើងសំអាងទៅលើបរិយាកាស ដែលគ្របដណ្តប់ដោយការភ័យខ្លាចនៅកូសូវ៉ូដែលជាឧបសគ្គរាំងបំពោះការខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីឲ្យបានទទួលនូវសក្ខីកម្មរបស់សាក្សី ។

ចោទធ្វើការគាបសង្កត់ទៅលើសាក្សី និងជនរងគ្រោះនានានោះបានទេ ហេតុដូចនេះហើយ គឺវានិងមានការបំផ្លាញភស្តុតាង ។

## ៦. សេចក្តីសន្និដ្ឋាន

៤៦. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា ស្នើឲ្យអង្គបុរេជំនុំជម្រះ បដិសេធចោលនូវបណ្តឹងឧទ្ធរណ៍ទាំងមូលរបស់មេធាវីការពារក្តី ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩

**សហព្រះរាជអាជ្ញា**

| | |
|---|---|
| **លោក យ៉េត ចរិយា** | **លោក** William SMITH |
| **សហព្រះរាជអាជ្ញារង** | **សហព្រះរាជអាជ្ញារង** |